# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *ចៀម សឿ ភេទប្រុស* **K08573**

*ជួបសម្ភាសជាមួយ ចៀម សឿ អាយុ៤៥ឆ្នាំ ជាម្ចាស់ប្រវត្តិរូប*

*មុខងារសម័យខ្មែរក្រហមៈ អ្នកយាមទួលស្លែង ស-២១*

*ភូមិស្នាយ ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*

*ធ្វើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៥*

*សម្ភាសដោយៈ អៀ ម៉េងទ្រី*

*សរុបៈ ៣៩ទំព័រ*

ទ្រីៈ បងសឿពួកយើងមកលើកនេះគឺចប់ជួបសម្ភាសជាមួយបងសឿឯង ហើយយើងមកលើកនេះគឺមកជាមួយទេវិទ្ធ, ហុរីណា ហើយហ្នឹងសារីណា ហើយពួកខ្ញុំមកលើកនេះ គឺមកសួរអំពីគំរោងដែលដាក់ថាគំរោងឲ្យមានការទទួលខុសត្រូវ គឺមានសំនួរនៅក្នុងក្រដាសនេះ ហើយពួកខ្ញុំហ្នឹងសួរបងសឿឯង តាមក្រដាសសំនួរនេះបន្តបន្ទាប់តាមសំនួរនៅក្នុង ក្រដាសនេះណា ហើយដោយសារពួកខ្ញុំធ្លាប់មកហើយឬក៏ធ្លាប់ជួបជាមួយបងសឿឯងម្តងដែរ តើបងសឿឯងមានអីឆ្ងល់ឬក៏មានសំនួរអីត្រូវសួរពួកខ្ញុំមុនហ្នឹងពួកខ្ញុំសួរបងសឿឯង?

សឿៈ ខ្ញុំអត់មានឆ្ងល់ទេបង ប៉ុនខ្ញុំចង់ឲ្យសួរអំពីការសំដែងការពិតហ្នឹងណា៎ ខ្ញុំចង់ឲ្យបងឯងនិយាយមកសួរខ្ញុំមក វាងាយស្រួល ខ្ញុំឆ្លើយដោះស្រាយ ។

ទ្រីៈ អញ្ចឹងបងសឿឯងជាអ្នកដោះស្រាយ?

សឿៈ ខ្ញុំដោះស្រាយនូវសំនួរដែលបងឯងសួរខ្ញុំ ទុកឲ្យខ្ញុំដោះស្រាយសំនួរពីប្រវត្តិរបស់ខ្ញុំមកវិញ ។

ទ្រីៈ សំនួរដំបូងសួរអំពីឈ្មោះ បងសឿឯងឈ្មោះពេញឈ្មោះអីដែរ?

សឿៈ ចៀម សឿ ។

ទ្រីៈ មានឈ្មោះអីផ្សេងទៀតដែលទេបងសឿ?

សឿៈ មានឈ្មោះ ចៀម ម៉ៅ ពីកាលដែលនៅជំនាន់នោះខ្ញុំឈ្មោះ ចៀម ម៉ៅ ។

ទ្រីៈ ហើយចុះនៅជំនាន់ណាដែលមានឈ្មោះ ចៀម សឿ?

សឿៈ ជំនាន់ឥឡូវហ្នឹងហើយ ។

ទ្រីៈ ហើយចុះបងសឿឯងដាក់ឈ្មោះនៅកន្លែងធ្វើការមានឈ្មោះអីដែរ?

សឿ៖ ចៀម ម៉ៅ ។

ទ្រី៖ ហើយចុះបងសឿឯងកើតនៅឯណាដែរ?

សឿ៖ ខ្ញុំកើតនៅភូមិស្នាយ ឃុំតាជេស ។

ទ្រី៖ នៅហ្នឹងភូមិស្នាយ?

សឿ៖ ភូមិស្នាយ ។

ទ្រី៖ កើតនៅឆ្នាំណាដែរ?

សឿ៖ ទេ! ខ្ញុំដូចជាភ្លេចឆ្នាំខ្ញុំដែរហើយ ។

ទ្រី៖ ឆ្នាំខាល ថោះអី?

សឿ៖ ខ្ញុំឆ្នាំជូត កើតនៅឆ្នាំ១៩៦០ ។

ទ្រី៖ ច្បាស់ហើយថាឆ្នាំជូត?

សឿ៖ ពីព្រោះខ្ញុំរៀនបានមួយឆ្នាំរដ្ឋប្រហារ ហើយខ្ញុំចេញទៅធ្វើជាទ័ពហ្មង ។

ទ្រី៖ បងសឿភូមិនេះនៅជាភូមិអីដែរ?

សឿ៖ នៅតែជាភូមិស្នាយដដែល ។

ទ្រី៖ បងសឿនៅក្នុងកាលពីរបបឆ្នាំ៧៥-៧៩ណា តើបងសឿឯងមានដែលឃើញដូចកាលដែលបងសឿ ដូរគ្រប់កន្លែងទាំងអស់ តើបងសឿ ឯងមានដែលឃើញគេសម្លាប់មនុស្សដែលទេកាលនៅជំនាន់ហ្នឹង?

សឿ៖ ខ្ញុំអត់ដែលឃើញទេ គឺឃើញនៅតែកន្លែងដែលខ្ញុំធ្វើការនៅទួលស្លែងហ្នឹងតែមួយទេ ដែលជាគុកតែមួយហ្នឹងទេដែលជា កន្លែងសម្លាប់មនុស្ស ដែលគេដាក់ខ្នោះគេដាក់គុកហ្នឹងគឺមានតែគុកទួលស្លែងមួយទេ បើថានៅសត្បូរនៅគៀនស្វាយ អាហ្នឹងគឺខ្ញុំបានឃើញគេយកមនុស្សទៅអន្លង់ឯកមែន ដែលនៅស្ទឹងជើងឯង ប៉ុនមិនដឹងជាគេយកទៅសម្លាប់ក៏មិនដឹង គេយកទៅណាក៏មិនដឹង ពីព្រោះឃើញតែគេដាក់ខ្នោះយកទៅ ។

ទ្រី៖ គេយកពីណាទៅដែរ?

សឿ៖ យកពីទួលស្លែងទៅ អាហ្នឹងគឺខ្ញុំនិយាយតាមការដាក់ស្ដែងណា ។

ទ្រី៖ គេយកទៅរបៀបម៉េច?

សឿ៖ ខ្ញុំអត់បានតាមដានគេដែរ ខ្ញុំអត់ដឹងដែរ ប៉ុនមនុស្សឲ្យតែវាយកទៅចងមុខគឺវាសម្លាប់ហើយ ។

ទ្រី៖ បងសឿឯងរៀបរាប់មើល ថាតើគេយកចេញពីអាគារណាហើយអ្នកណាដែលជាអ្នកយកទៅហើយគេដាក់ស្អីទៅ?

សឿ: មានតែបងហ៊ុយហ្នឹងមួយហើយដែលជាអ្នកយកទៅនោះ ពីព្រោះអីគាត់នៅកងពលជាមួយគ្នា ហើយគឺមានតែបងហ៊ុយ មួយហ្នឹងឯង ដែលជាអ្នកដឹកទៅនោះហើយអ្នកដែលដឹកទៅហ្នឹង គឺមានបងទ្រី នេះមួយដែលនៅជាមួយហ៊ុយហ្នឹង ដែលជាអ្នកបើកឡានឲ្យហ៊ុយ ហើយខ្ញុំអត់មានចំពាក់ចំប៉ិនអីទេ ហើយឃើញដាក់ស្តែងមួយពីរទៀតគឺនៅពេទ្យឆ្កួតដែលគេ ហៅពីដើមនោះ ដែលនៅព្រែកត្នោតនៅកន្លែងហ្នឹងឃើញសម្លាប់ច្រើនដែរ កាលហ្នឹងខ្ញុំនៅសត្បូរការងារខ្ញុំនៅយាម នៅហ្នឹងឃើញគេយកមកសម្លាប់ច្រើនដែរ គឺមានគុកនៅកន្លែងមួយទៀតគុកនៅព្រែកត្នោត ។

ទ្រី: អញ្ចឹងខ្ញុំបញ្ជាក់ម្តងទៀតគឺបងសឿឯងបានឃើញតែគេដាក់មនុស្សទៅក្នុងឡានពីទួលស្លែងទៅទេតែអត់មានឃើញគេ សម្លាប់ទេ?

សឿ: អត់មានឃើញគេសម្លាប់ទេ មិនបានឃើញគេសម្លាប់ទេពីព្រោះខ្ញុំជាកងទ័ពដែលនៅខាងក្រៅគឺមិនបានឃើញគេសម្លាប់ទេ បើថា ពៅ គេដឹងពីព្រោះគេបានដាក់ស្តែងហ្នឹង ។

ទ្រី: ចុះពេលដែលគេយកទៅហ្នឹង តើគេធ្វើម៉េចទៅគេមានចងភ្នែកអីដែលទេ?

សឿ: ខ្ញុំឃើញគេចងភ្នែក ឲ្យតែគេចងភ្នែកគឺមានតែងាប់ហើយ ឲ្យតែរុំមុខគឺអត់ឃើញមកវិញហើយវាមិនបានតាមដានគេ ថាពេលដែលគេយកទៅហ្នឹងមិនដឹងជាគេយកមកវិញក៏មិនដឹងគេបញ្ជូនទៅខាងណាក៏មិនដឹងតែដាក់ខ្មោះហើយប្រហែល ជាងាប់ក៏មិនដឹង ។

វិទ្ធ: ប៉ុន្មាននាក់ដែលពូកាលដែលពូឃើញដាក់ឡានហ្នឹង?

សឿ: ទេ! មិនដឹងដែរ មួយឡានអាឡានចិននោះមិនដឹងជាប៉ុន្មានទេហើយក៏មិនហ៊ានរាប់ហ្នឹងគេដែរ ២០-៣០នាក់ក៏មិនដឹង បើគេយកទៅបាត់ៗហើយយើងក៏មិនដឹង បើគេការងារផ្សេងហើយយើងមានការងារផ្សេង ដូចថាបងឯងផ្សេងទៅ ហើយខ្ញុំធ្វើការផ្សេងទៅអញ្ចឹងណា ។

វីណា: ចុះពូធ្វើការងារអីគេដែរ?

សឿ: ខ្ញុំកងទ័ពផ្សេង ហើយគេឲ្យនៅយាមខ្សែរក្រវាត់នៅខាងក្រៅ ដូចថាមួយក្រុមនៅតាមមាត់ទន្លេអីចឹងទៅណា នៅកន្លែងណាក៏ដោយឲ្យតែនៅក្នុងកងពលហ្នឹង គឺអ្នកយាមនៅខាងក្រៅគឺនៅតាមខាងក្រៅអ្នកដែលយាមនៅខាងក្នុងគឺនៅខាងក្នុងអ្នកសួរនៅតាមអ្នកសួរ អ្នកកត់គេនៅតាមអ្នកកត់ ហើយឆក់អីគឺគេនៅតាមផ្សេងៗដាច់ដោយឡែក គឺដូចជាអ្នកជិនាញការ, ប៉េអឹមប៉ូលិសអីនៅសព្វថ្ងៃអញ្ចឹង គឺគេអត់មានឲ្យយើងនៅធ្វើការងារច្របូកច្របល់អីជាមួយនឹងគេទេ ។

ទ្រី៖ ហើយកន្លែងដែលគេសម្លាប់ហ្នឹងគឺមិននៅទួលស្លែងទេ បើថាគេចង់សម្លាប់មនុស្ស គឺគេត្រូវយកមនុស្សចេញពីទួលស្លែងហ្នឹងទៅ?

សឿ៖ ហ្នឹងហើយ ។

ទ្រី៖ តែដល់ពេលដែលគេយកទៅកន្លែងផ្សេងគឺ បងសឿឯងអត់មានបានដឹងទេ?

សឿ៖ អត់ដឹងទេ ។

ទ្រី៖ ពីព្រោះយើងនៅតែទួលស្លែង?

សឿ៖ បា៎! ។

ទ្រី៖ ចុះនៅទួលស្លែងហ្នឹងដូចថាគេវៃសួរចម្លើយម៉េខ្លះទៅ?

សឿ៖ អាហ្នឹងគឺថាយើងអត់បានទៅជិតគេទេ គឺអ្នកសួរចម្លើយគឺជារឿងរបស់គេទេ គេជាអ្នកសួរចម្លើយគឺគេវៃទៅណា ខ្ញុំវិញគឺតួនាទីខ្ញុំត្រូវដើរយាមតាំងពីស្តាតមក ហើយគេឲ្យបែកមកវត្តទួលទំពូង ហើយមកដល់ជុំវិញលូទឹកស្អុយហ្នឹង ហើយលឺសូរតែមនុស្សស្រែកនៅពេលដែលគេសួរចម្លើយទេ ហើយយើងអត់មានទៅឡូកឡំជាមួយការងាររបស់គេទេ តែឡូកឡំហាមាត់មួយម៉ាត់គឺជាប់ហើយ តែមួយយប់ស្អែកបញ្ជូនទៅហើយ ។

ទ្រី៖ អញ្ចឹងបងសឿ ធ្លាប់លឺសំលេងអ្នកទោសស្រែកដែរ?

សឿ៖ លឺស្រែកណា ហើយរាយការណ៍ប្រាប់ទាំងអស់បា៎ទ! និយាយមិនឈឺម៉េចបើមនុស្សណា ។

ទ្រី៖ ហើយអាហ្នឹងនៅក្នុងឆ្នាំណាដែរ?

សឿ៖ ឆ្នាំ៧៧ ។

ទ្រី៖ ហើយបងសឿ ឯងកំពុងតែធ្វើអីបានលឺ?

សឿ៖ កំពុងតែដើរ ។

ទ្រី៖ ដើរធ្វើអី?

សឿ៖ ដើរយាមការពារ ដែលគេការពារកុំឲ្យមានអ្នកទោសអីលួចរត់ ។

ទ្រី៖ ហើយបងសឿ ឯងលឺចំងាយប៉ុណ្ណាទៅពីទួលស្លែងបានលឺ?

សឿ៖ ហ៊ឺ! អាហ្នឹងខ្ញុំពិបាកប៉ាន់ស្មានណាស់គឺខ្ញុំគ្រាន់តែឃើញពីកន្លែងថ្នល់ហ្នឹង គឺពីលិចថ្នល់ពីរវត្តផ្លូវបត់នេះដែរ ដូចថាពីទួលស្លែងនេះទៅ ហើយខ្ញុំដើរពីកាច់ជ្រុងនេះទៅគឺវាឆ្ងាយដែរ ហើយកន្លែងដែលគេសួរចម្លើយគឺនៅជិតលូរទឹកស្អុយនៅជិត ផ្ទះតាឌុច នៅកន្លែងតាឌុច ស្នាក់ការហ្នឹងដែលជាប្រធានកងពលហ្នឹង ហើយដើរមួយជុំវិញហ្នឹងមកតែកន្លែងគុកទួលស្លែង គឺខ្ញុំអត់

ហ៊ានចូលទៅទេ ហើយអាកន្លែងគុកទួលស្លែងដែលនៅជាប់ផ្លូវនៅខាងជើងណោះ តែមិនដឹងជាគេហៅថាជាផ្លូវអី ទេហើយខ្ញុំក៏អត់ស្គាល់ដែរ ។

ថ្វី: ហើយម៉េចបានជាបងសឿ ដឹងថាសម្លេងហ្នឹងជាសម្លេងអ្នកទោស?

សឿ: ដឹងថាជាសម្លេងអ្នកទោស

បើដឹងថាគេឲ្យនៅយាមការពារនៅខាងក្រៅហ្នឹងគឺដើម្បីការពារកុំឲ្យអ្នកទោសរត់ចេញ ។

ថ្វី: អត់មានច្រឡំជាមួយសម្លេងពួកកម្មាភិបាលអីទេ?

សឿ: អត់ទេ ។

ថ្វី: លឺសម្លេងម៉េចខ្លះបានដឹងថាជាសម្លេងអ្នកទោស?

សឿ: ខ្ញុំលឺគេសួរថា លឺមួយភ្លែតនៅពេលដែលគេអត់មានឃើញយើងអញ្ជឹងណា ហើយលួចស្តាប់គេប្រហែលជា១០ម៉ែត្រ អីពីថ្នល់អញ្ជឹងណា ហើយនៅហ្នឹងគឺវាលឺបំពងណាបំពងផ្ទះហ្នឹងលឺថាពួកហែ្អងចូលដៃយួនប៉ុន្មាននាក់ហើយនៅខាងណាអីចឹងទៅ ឬហ្អែងចូលកាសេបេហ្នឹង សេអ៊ីអាអីទៅ ហើយខ្ញុំគ្រាន់តែស្តាប់បានប៉ុណ្ណេះហើយដើរចេញទៅទៀតហើយ ហើយបើថាហ្អែងនិយាយមិនច្បាស់នាំគ្នាដាក់ទៀតទៅ ហើយស្រែកទៀតទៅ ហើយយើងលឺស្រែកមួយវិះបាត់មាត់ៗ ទៅហើយយើងក៏ដើរចេញទៅ គឺអត់មានហ៊ាននៅទេ តែនៅហើយវាក្រឡេកឃើញគឺយើងហើយជិនួសអ្នកទោសហើយ ។

ថ្វី: ហើយពីណាគេជាអ្នកសួរចម្លើយ ។

សឿ: ឈ្មោះខន, បងធីហើយបងធីហ្នឹងសួរចម្លើយផងខាងឯកសារផង អាទ្រីគេជាអ្នកដឹក ហើយហ៊ុយគេជាអ្នកចងជាអ្នកនាំទៅសម្លាប់ ហើយឈ្មោះអីទៀតទេ ហើយខ្ញុំវាភ្លេចច្រើនណាស់មានសឿនជាអ្នកសួរចម្លើយហើយហ្នឹងអាច្រឹកនេះ ជាអ្នកសួរចម្លើយហ្នឹងវែឯកសារអន្តុលីលេខ គឺខាងប្រវត្តិរូបសួរចម្លើយពីអ្នកទោស ។

ថ្វី: ហើយពួកហ្នឹងមានតួនាទីម៉េចដែរ?

សឿ: ទេ! អារឿងតួនាទីគឺខ្ញុំអត់ដឹងទេ ពីព្រោះខ្ញុំជាយុទ្ធជន ។

ថ្វី: ចុះពួកអ្នកទោសហ្នឹងមកពីណាដែរ?

សឿ: ទេ! បើថាអ្នកទោសគឺខ្ញុំអត់ដឹងថាគេមកពីណាទេ ពីព្រោះខ្ញុំអត់បានតាមដានឯកសារអត់ដឹងមិនដឹងជាគេយកពីណាមក ទ័ពក៏មានហើយប្រជាជនក៏មាន កម្មាភិបាលអីក៏មានតែមិនដឹងជាគេយកមកពីណា គឺគ្រាន់តែគេថាអ្នកដែលនៅ ការពារនៅខាងក្រៅប្រើងប្រែង ។

ថ្វី: ចុះពូយល់ថាការសួរចម្លើយ ហើយហ្នឹងការដែលគេធ្វើទារុណកម្មហ្នឹង តើវាមានបញ្ជារមកពីខាងលើដែលទេ?

សឿ: ទេ! ទាល់តែមានឪពុកប្រាប់ហើយបានអាកូនហ្នឹងវាហ៊ានធ្វើ បើឪពុកប្រាប់ថាមិនឲ្យទៅធ្វើការបែបមិនហ៊ានទេយ៉ាង ។

ថ្វី: ពីណាគេដែលពូថាជាឪពុកហើយជាអ្នកដែលបញ្ជារ?

សឿ: ឌុចហ្នឹងហើយ ពីព្រោះអាឌុចជាអ្នកដែលនៅកាន់កាប់នៅហ្នឹង ។

ថ្វី: ចុះមានពីណាគេដែលនៅលើឌុចហ្នឹងទៀតដែលទេ?

សឿ: ទេ! បើថានៅពីលើទៀតខ្ញុំអត់ស្គាល់ ខ្ញុំបានប្រាប់ហើយថាមានតែឌុច ទេដែលនៅឈរជើងនៅហ្នឹង ហើយមាឈ្មោះហ៊ិ មួយទៀត ។ ហ៊ិហ្នឹងនៅសំណាក់ការជាមួយគ្នាហ្នឹង នៅជាមួយឌុចហ្នឹង ប៉ុនគេថាឈ្មោះអ៊ីទេប្រធាននោះម៉ោអ៊ីទេ ហើយ ដែលឈ្មោះ ប៉ុល ពត នោះក៏ខ្ញុំអត់មានឃើញដែរ ដែលគេថា ប៉ុល ពត នោះគឺឃើញតែរូបចំលាក់ដែលគេគូរឲ្យពួកខ្ញុំមើលនៅពេលដែលពួកខ្ញុំទៅដំបូងនោះទេ គឺអត់មានឃើញគាត់ទេ ។

ថ្វី: អញ្ចឹងអត់មានដែលឃើញអ្នកធំណាផ្សេងទៀតដែលទេ?

សឿ: អត់មានដែលបានឃើញទេ គឺឃើញតែឌុច, ហ៊ិ, ប៉េង តែបងប៉េងគាត់ស្លាប់យូរហើយគាត់ស្លាប់ នៅពោធិ៍ចិនតុង ។

ថ្វី: ចុះមានឃើញឌុចហ្នឹងសួរអ្នកទោសហើយវៃអ្នកទោសដែលអត់?

សឿ: មិនចាំបាច់តែអ្នកទោសទេសូម្បីតែខ្ញុំក៏គាត់វៃដែរ កងទ័ពក៏ដែរឲ្យតែថាមិត្តឯងហើយ ស្តាប់ឬមិនស្តាប់ក៏វៃដែរ ។

ថ្វី: ពូដែលជួបខ្លួនឯងឬក៏របៀបម៉េច?

សឿ: បើឌុចជួបហើយ ជួបខ្លួនខ្ញុំតែហ្មង ។

ថ្វី: មើ! ពូនិយាយមើល?

សឿ: គាត់ថាបើថាមិត្តឯងនៅយាមការពារកន្លែងហ្នឹងមិនបាន ខ្មាំងរួចនៅច្រកហ្នឹង ឬក៏ខ្សែរក្រវ៉ាត់រួចនៅច្រកនេះ មិត្តឯងទទួលខុសត្រូវ មិនបានមិត្តឯងជួបជំនួសអ្នកទោសហើយ បើគាត់ថាមិត្តឯងហើយមិនចាំបាច់ដេកទេគឺរៀបចំខោរអាវ ឲ្យហើយទៅ អាហ្នឹងគឺឌុច បើថាបងហ៊ិហ្នឹងគឺគាត់ធម្មតាទេ សព្វថ្ងៃនេះគឺខ្ញុំនៅខឹងអាឌុចតាំងពីខ្ញុំរត់ទៅអមលាំងណោះ រត់ពីយួនទៀតទៅខាងលើទៀត គឺគាត់ទៅតាមសម្លាប់ពួកខ្ញុំនៅក្រាំងត្នោតខាងជើងអមលាំងទៀតណា គាត់ថាពួកខ្ញុំជាដៃជើងយួន ហើយនៅទ័ពជាមួយគាត់សោះណា ហើយគាត់ចោទថាយួនណា គឺនៅកងពល

ជាមួយគាត់សោះណានៅតែ គាត់ចោទថាខ្ញុំយួនណា បានខ្ញុំតូចចិត្តណា បានខ្ញុំខឹងខុចណាបាន ជាកងទ័ពស្មោះត្រង់ហើយ នៅកងពលជាមួយគ្នាហើយ គាត់ជាអ្នកគ្រប់គ្រងខ្ញុំ ហើយឲ្យតែខុសគាត់ទៅតាមសម្លាប់កងទ័ពហ្នឹងទៀត អស់ប៉ុន្មាននាក់ពួកខ្ញុំនោះយ៉ាងអាខ្មៀនអី មិនស្លាប់នៅក្រាំងត្នោត ខ្ញុំនឹកឃើញអន់ចិត្តតែណា តែបើថាថ្នាក់លើដូចជាតាម៉ុក អីអត់ដែលឃើញគាត់មកប៉ះពារអីទេ អានេះនិយាយតាមព្រះធរណី គាត់ជាអ្នកបញ្ជារហើយហៅកងទ័ពសិទ្ធតែជាកូនអាអូន នៅប៉ៃលិននៅឯណាក៏ដោយ គឺគាត់អត់ដែលមើលងាយអត់ដែលសម្លាប់អ្នកណាទេ បើថាខុសអីហើយថាបើហ្អែងមិនស្រួលនៅទៅអូន អាចៅនៅទៅ ហើយខ្ញុំទើបតែមកជួបជាមួយតាឌុចនេះ ដែលគេបញ្ជូនខ្ញុំពីស្រុកយួននោះមកគឺមកនៅត្រឹមតាឌុចហ្នឹងហើយ គឺនៅឆ្នាំ ៧៧ មកទល់ហ្នឹងឆ្នាំ៧៩ ដែលវៀតណាមគេចូលមករំដោះហ្នឹង នៅបានមួយឆ្នាំជាង ហើយឃើញគេដឹកពួកបូព៌ាមក សម្លាប់ហ្នឹង បានខ្ញុំនឹកឃើញថាចុំលេងដឹកមកសម្លាប់ទាំងអស់ ។

ទ្រី: ពូនិយាយរៀបរាប់ពីបូព៌ាហ្នឹងបន្តិចមើល?

សឿ: មុនដំបូងដែលគេដឹកពួកហ្នឹងមក គេប្រមូលមកគឺគាត់ថាដឹកកងទ័ពបូព៌ាហ្នឹងកងទ័ពមជ្ឈិមឲ្យមកមើលកុននៅភ្នំពេញ ហើយដឹកមកហ្នឹង គេដកកងទ័ពថ្មីហ្នឹងឲ្យទៅទុកនៅកន្លែងផ្សេងទៅណា ហើយគេឲ្យពួកចាស់ហ្នឹងមកមើលកុននៅភ្នំពេញ មិនបានមើលកុននៅភ្នំពេញទេ ស្រាប់តែមកដល់ត្រឹមអ្នកលឿងនេះដកកាំភ្លើងគ្នាទុកនៅឃ្លាំងអ្នកលឿងនេះ ហើយគ្នាមកដោយទទេរ ដល់មកដល់ភ្នំពេញហ្នឹងមិនបានមើកកុនទេ គ្រាន់តែចុះពីលើឡានមកព្រុះៗហើយអង្គរក្សគេនោះសុទ្ធតែមាឌគ្រឹកៗ ហើយគេបញ្ឈរនៅហ្នឹងហើយឲ្យលើកដៃទៅដាក់ខ្នោះគ្នាបន្តទៅ ហើយដាក់ខ្សែរដឹកចូលទៅតែហ្មងហ្នឹង ។

ទ្រី: ចូលទៅឯណា?

សឿ: ទៅទួលស្លែងហ្នឹង ។

ទ្រី: អញ្ចឹងអត់មានបានទៅមើលកុនទេ.?

សឿ: អត់មានបានទៅមើលកុននៅឯណាទេ ។

ទ្រី: ហើយគេយកចូលទៅឯណា?

សឿ: ចូលទៅទួលស្លែងហ្នឹងឯង ។

ទ្រី: ហើយក្រោយមកគេធ្វើម៉េចទៀត?

សឿ: ដឹងអី ដល់តែខ្ញុំនៅក្រោយគេហ្នឹងខ្ញុំថា ពួកហ្នឹងទៅបាត់មិនដែលបានមកវិញទេ ខ្ញុំនៅឯសមរភូមិណាដល់អញ្ចឹងគេដក ពួកខ្ញុំមជ្ឈិមហ្នឹងមកទៀត កងពល៧០៣ហ្នឹងដកពីក្រុមមកមើលទៀត

ចំណុះនៅជាប់ព្រំដែនណោះ ដល់តែដកមកហ្នឹង បានជាខ្ញុំឃើញគេ គេយកតែអ្នកនៅភូមិភាគបូព៌ា ហើយគេដកខ្ញុំទាំងពីរក្រុមហ្នឹងយកមកដល់គេនៅរៀនសូត្រឯកសារ រៀនអីបញ្ចឹងទៅ ហើយខ្ញុំអត់មានចេះអក្សរអីហ្នឹងគេខ្ញុំអត់រៀន ដល់នេះទៅគេពន្យល់អញ្ចឹងទៅ ហើយគេថាពួកអានេះនៅការពារនៅត្រង់នេះ ក្រុមនេះត្រូវនៅការពារនៅខាងក្រៅ ក្រុមនេះនៅខាងក្នុងនៅដើម្បីយាមអ្នកទោស ខ្ញុំលឺគេថា នៅយាមអ្នកទោសនេះបានខ្ញុំញាក់ណា មិនដឹងជាឪពុកឬម្ដាយអញ ឬស្អីទេម្ដងនេះ ស្រាប់តែខ្ញុំសុំគេមើលហើយគេហៅទៅប្រជុំអញ្ចឹង ទៅដល់ឃើញគុកទួលស្លែងហើយខ្ញុំទើបតែហ្នឹងឃើញនៅហ្នឹងមុខហ្នឹងហើយ ចូលទៅដល់ឃើញគេតំរង់ជួរគ្នាហើយខ្នោះដាក់មួយតំរង់ជួរគ្នាទៅ អាពៅអីសួរទៅខ្ញុំថាបើអស់ពីគេទៅមានតែយើងហើយ អស់តែមួយអាហ្នឹងគឺ មានតែយើងហើយ ហើយអាពៅវាថាកុំតែគិតផាប់ចោលទៅ ហើយវាគ្មានស្អីទៅតដៃជាមួយហ្នឹងគេទៀតពីព្រោះកាំភ្លើងគេដកអស់ហើយ ដល់អញ្ចឹងទៅ ពួកខ្ញុំគេអត់ទាន់ដកទេណា គេអត់ទាន់បញ្ចូលដាក់ខ្នោះអីទេ ហើយដល់នេះទៅ ស្រាប់តែគាត់ហ្នឹងថា ឥឡូវមិត្តឯងនាំគ្នាចេញមកក្រៅសិន ដល់ ខុចហ្នឹងគេប្រជុំហើយហាហ្នឹងគេប្រជុំគេថាក្រុមមិត្តឯង ដែលជាក្រុមទី១០នេះយាមនៅខាងក្រៅ មួយខ្សែរក្រវ៉ាត់ម៉ាទួលស្វាយព្រៃនេះទាំងអស់ តាំងពីដើមនាទីគឺគ្មានឲ្យអ្នកណាចេញចូល គ្នាមួយយប់ទាំងអស់១០អ្នកនាំគ្នាដើរជុំវិញទាំងអស់ ហើយខ្ញុំសួរថាអញ្ចេះនាំគ្នាដេកផងដើរលើថ្នល់ផង ហើយកាលហ្នឹងអត់មានឡានដូចយើងនៅឥឡូវផង បើថាមានដូចយើងនៅឥឡូវផាប់បាត់ហើយមានដូចឥឡូវផាប់បាត់ហើយ ឲ្យយាមហើយអ្នកណាយាមបានគ្រប់ជ្រុងផង បើអត់មានរបងផង ហើយអាររបងនេះគឺទើបតែធ្វើទេ គេទើបតែហ្នឹងធ្វើនៅឥឡូវនេះទេ កាលដែលខ្ញុំទៅនេះគឺទើបតែឃើញគេធ្វើទេ ហើយនៅកាលពីមុនអត់មានធ្វើទេគឺវាលល្វឹង សុទ្ធតែជារបងថ្មទេ ។

ទ្រី: ពេលដែលគេឲ្យនៅយាមពួកបូព៌ាហ្នឹងគេប្រាប់ថាម៉េចដែរ?

សឿ: គេគ្រាន់តែប្រាប់យើងនៅឲ្យនៅការពារនៅខាងក្រៅហ្នឹង ឲ្យប្រយ័ត្នមែនទែន ឲ្យតែនៅយប់ឡើងគេដឹកទៅអស់ហើយ ។

ទ្រី: ប្រហែលជាប៉ុន្មានរយទៅ?

សឿ: ទេអានេះខ្ញុំមិនបានរាប់ទេ ។

ទ្រី: ប៉ុន្មានឡានទៅ?

សឿ: ប្រាំឡានណា អាឡានចិនអាំដែលមានកង់ប្រាំមួយៗនោះណា ។

ទ្រី: នៅក្នុងមួយឡានមានប៉ុន្មានអ្នកទៅ?

សឿៈ ដូចខ្ញុំបានជំរាបពីមុនថាអាការសាររហ្នឹងគឺយើងវាអត់បានទៅជិតគេ ។

ថ្វីៈ កាលហ្នឹងបងសឿឯងនៅឯណាដែរ?

សឿៈ កាលហ្នឹងខ្ញុំនៅហ្នឹងដែរ តែគេដឹកពួកបូព៌ាមកថែមទៀត ។

ថ្វីៈ ពេលឡានដែលគេមក តើបងសឿឯងនៅកន្លែងណាហើយចម្ងាយប៉ុណ្ណាបាន បងសឿឯងឃើញ?

សឿៈ នៅប៉ុណ្ណឹង ។

ថ្វីៈ នៅយាមនៅកន្លែងហ្នឹងហ្មង?

សឿៈ ខ្ញុំនៅដើរទៅអញ្ចឹង ពីឈប់ឡាននៅច្រកអញ្ចឹងហើយខ្ញុំឈរនៅចម្ងាយអញ្ចឹង ។

ថ្វីៈ ហើយនៅពេលដែលឡានគេឈប់ តើគេឲ្យចុះមករបៀបម៉េច?

សឿៈ គេឲ្យចុះមកម្តងមួយទៅណា ហើយគេឲ្យតំរង់ជួរទៅណា គេតំរង់ជួរទៅគេថាលើកដៃ ដល់គេឲ្យលើកដៃអញ្ចឹងទៅហើយ គេដាក់ខ្នោះគ្នាទៅ ។

ថ្វីៈ ចុះនៅពេលដែលឡានគេមកតើឌុចមាននៅហ្នឹងដែរអត់?

សឿៈ គេបញ្ជារនៅហ្នឹងស្រេចហើយ ។

ថ្វីៈ គេឈរនៅហ្នឹង?

សឿៈ អត់ទេ! តែគេនៅខាងក្នុង នៅក្នុងការិយាល័យគេហ្នង់ហើយនៅកងពលគេហ្នឹងហើយ គេជាអ្នកនៅគ្រប់គ្រងនៅហ្នឹង មកឈរទាំងអស់ ហើយឌុចហ្នឹងក៏គេមកឈរមើលដែរ ។

ថ្វីៈ ពូឃើញគាត់នៅឈរមើលដែរ?

សឿៈ ឃើយ បើថាឲ្យខ្ញុំទៅឥឡូវស្គាល់ ។

ថ្វីៈ គាត់នៅឈរមើលអីគេ ។

សឿៈ នៅឈរអ្នកដែលចូលទៅកន្លែងណាអីចឹង ហើយគាត់ឃើញពួកខ្ញុំគាត់ថាពួកមិត្តឯង ដែលនៅខាងក្រៅគឺនៅខាងក្រៅទៅ មិនចាំបាច់មកឈរមើលគេទេ ។

ថ្វីៈ ចុះពូមានដឹងថាពួកហ្នឹងគេយកទៅខាងណាទៅ?

សឿៈ មិនដឹង ដុតតែពីហ្នឹងទៅមិនដឹងជាគេយកទៅខាងណាទេ ។

ថ្វីៈ ចុះនៅពេលដែលគេយកចេញទៅវិញពូមានដែលជួបទេ?

សឿៈ អត់ជួបទេ ។

ថ្វីៈ តែដល់ពេលក្រោយមកអត់ដែលឃើញពួកហ្នឹងទេ?

សឿៈ អត់ឃើញ តែដល់ស្អែកឡើងឃើញគេដឹកមកទៀត ខ្ញុំដើរអញ្ចឹងទៅឃើញគេដឹកមកទៀត?

ទ្រី៖ ប៉ុន្មានឡានទៅ?

សឿ៖ ប្រាំឡានៗអញ្ចឹងណា តែមិនដឹងជាគេបញ្ជូនទៅខាងណាខ្ញុំអត់ដឹង ។

ទ្រី៖ ប្រហែលជានៅឆ្នាំណាដែរ?

សឿ៖ នៅឆ្នាំ៧៧ខែ៧ហ្នឹងកំពុងតែតឹងហើយ ហើយដល់ពេលចូល៧៨ហ្នឹងគឺកំពុងតែសម្លាប់ហើយ តែមិនដឹងជាគេយកទៅ សម្លាប់នៅឯណាមិនដឹង ។

ទ្រី៖ អញ្ចឹងបងសឿឯងឃើញតែគេដឹកចូលតែអត់មានដែលឃើញគេដឹកចេញទេ?

សឿ៖ ឃើញគេឈប់គេដាក់ខ្នោះឃើញ ប៉ុន្តែអារឿងដែលគេដឹកចេញអត់ឃើញ នៅក្នុងពីរថ្ងៃគឺគេដូរគ្នាម្តងដូចថាដូរខ្ញុំឲ្យនៅ ប៉ែកអញ្ចេះទៅ ហើយគេទៅនៅខាងក្រៅទៅ ហើយគេមកនៅប្រចកគេខាងណោះវិញទៅអាហ្នឹងគឺវាអញ្ចេះទេ អាហ្នឹងគឺ ការសំដែងរបស់ខ្ញុំគឺការពិតណាស់ខ្ញុំប្រាប់ទៅ ខ្ញុំអត់មានចេះភូតភរទេពីព្រោះខ្ញុំខឹងថាខ្ញុំអត់មានឪពុកម្តាយអីហ្នឹងគេដែលទេ មិនដែលមានហ្នឹងគេផង ។

ទ្រី៖ ចុះពូមានដែលស្គាល់ជួបអ្នកទោសដែលគេដឹកចូលគុកហ្នឹងដែលទេ?

សឿ៖ អត់ស្គាល់ អត់ដែលជួបផង សូម្បីតែគ្នាឯងក៏វាមិនដែលឲ្យជួបមុខផងហ្នឹង អាមួយនោះដែលកកោះនោះក៏ស្លាប់ ដាប់គុកនៅហ្នឹងដែរហ្នឹង ធ្វើទ័ពជាមួគ្នាក៏វាមិនដែលឲ្យឃើញមុខផងហ្នឹងតែឃើញមុខហ្នឹងវាឆ្លើយដាក់ឯកសារផាប់ទាំងអស់ហ្នឹង អញ្ចឹងហើយទាល់តែយើងគេច ដូចថាបងឯងអញ្ចឹងនៅសួរជាមួយខ្ញុំអញ្ចឹងគឺវាថាជាខ្មាំងឥឡូវហើយ ។

វីណា៖ ចុះពូមុនដំបូងធ្វើម៉េចបានជាពូចូលមកធ្វើការនៅកន្លែងហ្នឹងបាន?

សឿ៖ មុនដំបូងខ្ញុំធ្វើជាកងទ័ពហើយវៃចេញពី លន់ នល់ នេះរួចវៃពីកំពង់ឆ្នាំអីរួចចប់ភ្នំពេញនៅឆ្នាំ៧៥ខែ១ ដែលគេហៅថា ៧មករានេះណា ហើយគេដកខ្ញុំនេះឲ្យទៅវៃយួនទៅទប់យួន គេបញ្ជូនទៅតាមអ្នកលឿងអញ្ចឹង ដល់ខ្ញុំទៅបានដេកមួយ យប់ ហើយដកឲ្យទៅរៀនបាញ់រឹករ៉ឺននៅព្រែកហូរ ហាត់រៀននៅហ្នឹងបាញ់អាគ្រោះបាញ់អីចោបានគេយកបញ្ជូនទៅ ហើយអ្នកដែលចេះស្ទាត់គេដកឲ្យទៅស្រុកយួន ដល់ទៅហ្នឹងទៅស្រាប់តែគេថាខ្លះកំលាំងកងទ័ពគេឲ្យដកមកខាងក្រោមខ្លះ មកនៅខាងក្រោយ ហើយពួកអាធំៗទៅខាងមុខហើយក្រុមហ្នឹងប្រហែលជាប៉ុនវរៈសេនាតូច តែខ្ញុំមិនដឹងជាប៉ុន្មានទេ មួយវរៈសេនាតូចហ្នឹងពីព្រោះខ្ញុំមិនបានរាប់ដែរដល់តែគេដកមកហ្នឹងខ្ញុំក៏សុំគេមកក្រោយដែរ តែមុនដំបូងប្រុងថាមក លេងម៉ែឪទេបានជាសុំគេម៉ោមក ហើយកាលដែលគេសុំគេមកហ្នឹងមិនដឹងជាគេយកមកឲ្យនៅយាមគុកទួលស្លែងឯណាអាហ្នឹងគឺអញ្ចឹងទេ ហើយមកយាមនៅគុកទួលស្លែងហ្នឹងដូចជាចាប់បូព៌ាមកសម្លាប់អញ្ចឹង តាម

ពិតគឺអាហ្នឹងគឺដាក់ស្ដែង ហើយ ដូចខ្ញុំប្រាប់ថាខ្ញុំបានឃើញដាក់ស្ដែងគឺខ្ញុំប្រាប់ដាក់ស្ដែង ហើយ ។

វីណាៈ អញ្ចឹងពេលដែលពូចូលធ្វើការនៅគុកទួលស្លែងហ្នឹង គឺនៅពេលដំណាលគ្នាហ្នឹងគេចាប់ពួកបូព៌ាមកដែរ?

សឿៈ បាទ! មកពីនោះបានប្រហែលជាបីខែ បីខែហ្នឹងមកនៅដូចថាមួយស្រួលដេកស្រួលស៊ីស្រួល អញ្ចឹងទៅ ស្រាប់តែដល់តែមានចេញគុក គឺមានគុកហ្នឹងតែហ្មង ដល់មកហ្នឹងគេចាប់ហ្នឹងតែហ្មងហើយគេថាឲ្យនៅយាមអ្នកគុក គេឲ្យនៅយាមអ្នក ទោសគឺខ្ញុំភ័យខ្ញុំហើយ ខ្ញុំថាអញអត់បានជួបឪពុកម្ដាយហើយ ពីព្រោះមនុស្សមិនទាន់ធំឯណាបើមនុស្សមិនទាន់ចេះស្អី ដងខ្លាចគេចង់ស្លាប់ ទើបអាយុកាលណោះត្រឹមតែ១៣ឆ្នាំ គ្រាន់តែឃើញបងៗនារីហៅគេសុទ្ធតែបង គេកំពស់ត្រឹម ណាក៏ហៅគេបងដែរហ្នឹង សឹងតែគេដេកអោបណោះ ។

វីណាៈ កាលហ្នឹងពូថាគេមកមួយវរៈសេនាតូចហ្នឹង តើវរៈសេនាតូចលេខប៉ុន្មាន?

សឿៈ ខ្ញុំវាអត់បានចាំលេខហ្នឹងហើយថា បានជាគាត់មកសួរអារឿងលេខហ្នឹងថាលេខប៉ុន្មានហើយខ្ញុំថាអត់ចាំហ្នឹងហើយថា ចាំតែក្រុមហ្នឹងហើយគឺក្រុមលេខ១០ ។

វីណាៈ ក្រុមលេខ១០ចុះមេពូឈ្មោះអីដែរ?

សឿៈ វាទៅវិញទៅមកហ្នឹង ដូនកាលគេប្រជុំទិទានគ្នាទៅហើយគេបង្កើនអានេះទៅដូនគេអោយអានោះទៅ?

វីណាៈ ឈ្មោះអីខ្លះទៅពូ?

សឿៈ អូរ! ខ្ញុំអត់មានចាំទេច្រើនណាស់ច្រើនស្រុកច្រើនភូមិណាស់ខ្ញុំអត់មានចាំទេ ដូចថាបងឯងមកនៅក្រុមខ្ញុំទៅហើយបង នេះមកនៅក្រុមខ្ញុំទៅច្របូកច្របល់គ្នាណាស់ អត់ស្គាល់គ្នាទេតែបើថានៅជាមួយគ្នាអញ្ចឹងរាល់ថ្ងៃបែបស្គាល់ តិចគេដូរ អានេះតិចគេដូរអានោះគឺខ្ញុំអត់និយាយការពិតបានទេ តែបើការពិតដែលនៅឃើញដាក់ស្ដែងនៅហ្នឹងគឺខ្ញុំបានឃើញការ ពិតដាក់ស្ដែងមែន ឃើញតែគេចងឃើញគេដាក់ពួកបូព៌ាពួកណាក៏ដោយឲ្យតែឃើញ ឃើញមែនឃើញតែគេចងតែដល់ ពេលដែលគេបញ្ចេញយកទៅសម្លាប់វាមិនដឹងជាគេយកទៅឯណា ។

ទ្រីៈ ខ្ញុំចង់ឲ្យបងសឿឯងប្រាប់ខ្ញុំណា ពីព្រោះបងសឿឯងស្គាល់ឌុចណា តើបងសឿឯងធ្លាប់ឃើញឌុចនៅកន្លែងណា ហើយ ធ្លាប់ឃើញឌុចនៅធ្វើអីខ្លះ?

សឿៈ ឃើញនៅតែបញ្ជារតែហ្មងហើយ ។

ទ្រីៈ ចុះគាតបញ្ជារបងសឿឯងថាម៉េចខ្លះ?

សឿៈ អត់មានដែលមកបញ្ហារខ្ញុំទេ គឺបញ្ហារតែហ៊ុយពីព្រោះគេនៅក្រុមរបស់គេនោះណា ពីរហ្នឹងគឺគេថានៅក្នុងចង្កោមរបស់ គេទេគឺអត់មានមកនៅជាមួយខ្ញុំទេ អ្នកបញ្ជារហើយបើថាមេប្រធានគឺហ៊ុយហើយ ។

ថ្វីៈ អញ្ចឹងនៅការបញ្ជាររបស់ហ៊ុយ?

សឿៈ ប៉ាទ! ។

ថ្វីៈ ចុះមានដែលមកប្រជុំដូចថាប្រាប់បងសឿងងអី?

សឿៈ ដែលមកប្រជុំនោះគឺមានតែហ៊ាទេ ដូចថាភូមិអញ្ចឹងមកប្រជុំប្រាប់យុំអញ្ចឹង គឺគេឲ្យខ្ញុំនៅប្រជុំនៅខាងក្រៅគឺគេអត់មាន ឲ្យយើងចូលទៅឡូកឡំអីជាមួយហ្នឹងគេទេ បើថាគេប្រជុំគឺគេប្រជុំរឿងការងារលាក់ការណ៍របស់គេទេ ។

ថ្វីៈ ចុះពូមានដែលឃើញគាត់ដែលទេ?

សឿៈ ជីក៏មិនដែលឃើញ ខ្ញុំឃើញគាត់ដើរមកបាយដើរមកអីអញ្ចឹងដែរ?

ថ្វីៈ រាងរូវគាត់អីម៉េចដែរ?

សឿៈ រាងស្ដើង ។

វីណាៈ ឃើញគាត់ប៉ុន្មានដង?

សឿៈ ហ៊្អ! ឃើញគាត់ញឹកដែរ មិនទៅភរកុហកអីទេឃើញគាត់ញឹកដែរហ្នឹង ហើយគេគាត់ហូបបាយអ្នកធំផ្សេងហើយអ្នក តូចគេហូបផ្សេង គឺគេហូបបាយដឹងម៉ោង ហើយគាត់ហូបបាយអត់ដឹងម៉ោងគឺគេឃ្លាននៅស្មើរណាគឺគេស៊ីស្មើហ្នឹង ហើយយើងដើរមកឃើញគេបាយ គឺយើងនៅឈរមើលគេចាំគេបាយរួចទៅបានយើងចូលទៅបាយក្រោយគេទៅ ដូចថាគេរៀបចំឲ្យមេៗរួចអញ្ចឹងទៅ គឺមានតែពួកហ្នឹងហើយគឺឃើញមានតែពីរហ្នឹងហើយ អត់មានអ្នកណាទៀតទេបើថា តាម៉ុក តាម៉ែនអីគឺខ្ញុំអត់មានស្គាល់ទេ អត់មានដែលឃើញគាត់ទេ ។

វីណាៈ មើលទៅគាត់ហ្នឹងជាមនុស្សម៉េចដែរឌុចហ្នឹង?

សឿៈ ប្រហែនតែហ្នងហើយ ជាមនុស្សសម្លាប់មនុស្សស៊ីមនុស្សហើយ ។

ថ្វីៈ ម៉េចបានជាពូហ៊ានសន្និដ្ឋានថាអញ្ចឹង?

សឿៈ ទេ! ខ្ញុំហ៊ានថាអញ្ចឹងហើយ បើថាអ្នកខុសអីនៅក្នុងគុកបន្តិចបន្តួចអីតែគាត់ថាដាក់គុកគឺដាក់គុកហើយ ។

ថ្វីៈ ថាអ្នកណាដែលខុសៗហ្នឹងចាប់ដាក់គុកហ្នឹង តើជាអ្នកណាខ្លះ?

សឿៈ ឌុចហ្នឹងហើយ ។

ទ្រី៖ អត់ទេ អ្នកដែលគេចាប់ដាក់គុកហ្នឹងណា?

សឿ៖ ទេ! អារឿងដែលគេមកចាប់ហ្នឹងគឺមានតែបញ្ជារតាហ៊ុយហ្នឹងហើយ ឌុចគាត់ថាហ៊ុយឯងទៅចាប់មិត្តនេះមួយមក?

ទ្រី៖ ហើយនៅក្នុងក្រុមបងសឿ ឯងមានអ្នកដែលគេចាប់អញ្ចឹងដែលអត់?

សឿ៖ មានមួយឈ្មោះអាតេងនោះ បងអាហុងនោះ?

ទ្រី៖ ម៉ឺ! បងសឿឯងនិយាយបន្តិចមើល?

សឿ៖ បងអាហុងហ្នឹងនៅក្នុងក្រុមជាមួយគ្នា នៅក្នុងក្រុមជាមួយគ្នាដែលនៅខាងក្រៅទេណា ហើយមុនដំបូងអាហុងហ្នឹងគេជាប្រធានក្រុម ដល់ប្រជុំយប់ឡើងកសាងខ្លួននេះ ហើយអាគ្នាឯងនេះមិនហ៊ានទិទានទេទៅទិទានគេផ្សេង ហើយដល់ពួកគេ ដែលមកស៊ើបការណ៍នោះ ហើយគេថាឯងនេះនិយមស្រុកខេត្តភូមិ ដល់អញ្ចឹងទៅនៅព្រលប់ឡើងនេះគេត្រូវចាប់អា ហុងនេះទៅប្រជុំណែនាំជាមួយអ្នកធំគេដែលជាអាឌុចហ្នឹងណា ហើយគេឲ្យហ៊ុយនេះទៅហៅ ដល់ទៅហៅហ្នឹងវាបាត់ មួយយប់អត់មានឃើញមកវិញ ដលដ់អញ្ចឹងទៅឌុច ហ្នឹងគេប្រាប់មិត្តហ៊ុយហ្នឹងឲ្យមកបង្កើនអ្នកណាឲ្យកាន់ជាមេក្រុមជំនួសសិនទៅ ពីព្រោះហុងគេទៅបំពេញភារកិច្ចថ្មីបាត់ទៅហើយ ខ្ញុំលឺគេថាអាភារកិច្ចថ្មីនេះបាត់ទៅរហូត ដល់អញ្ចឹងខ្ញុំទៅ សួរអាពៅនេះហើយអាពៅនេះវាថាចូលគុកបាត់ហើយ គេចាប់ដាក់គុកបាត់ហើយ ហើយខ្ញុំថាម៉េចបានដាឯងដឹង អាពៅថាអញលឺបងអញស្រែកអញដឹង ហើយកាលហ្នឹងគេយកអាពៅហ្នឹងទៅយាមគុកបងឯងនេះទៀតណា គឺគេឲ្យមកយាមអាគុកដែលគេដាក់បងឯងនេះទៀត គឺពេលដែលគេដកអាហុងហ្នឹងមកចូលគុកហើយគេដកអាពៅហ្នឹងឲ្យចេញពី ក្រុមខ្ញុំឲ្យមកយាមនៅក្នុងគុកនេះទៀត ហើយខ្ញុំគេឲ្យទៅប្រជុំនៅក្រុមផ្សេងទៀត ហើយអាពៅវាប្រាប់ថាបងអញស្លាប់ ហើយហើយខ្ញុំថាម៉េចបានដាឯងដឹង ហើយនៅកាលហ្នឹងជួនគ្នានៅពេលបាយ ហើយខ្ញុំសួរថាអាពៅម៉េចហើយអា ហុង ជាប់គុកបាត់ហើយនៅទួលស្លែង វាស្រែកដ្តាំទៀតថាបើហ្អែងនៅរស់រានមានជីវិត ហ្អែងទៅប្រាប់ម្តាយអញផង ថាអញងាប់ហើយ ហើយអាប្អូនហ្នឹងនៅយាមគុកហ្នឹងនៅហ្នឹងអត់មានហ៊ានធ្វើអីទេ ពីព្រោះវាខ្លាចគេឆ្លើយដាក់បងប្អូន ហើយអាហ្នឹងវាអត់មានឆ្លើយដាក់បងប្អូនទៀត គឺអត់មានជាប់ប្រវត្តិអីទេ ។

ទ្រី៖ ហើយម៉េចបានជាពូដឹងថាឌុចជាអ្នកបញ្ជារឲ្យយកទៅ?

សឿ៖ គឺមានឯកសារដែលជាមេមកពីក្នុងនោះហើយថា បើគេថាបងឌុច ។

ទ្រី៖ គាត់និយាយថាម៉េច?

សឿ៖ បងឌុចកន្ធឿរនោះ គេជាប្រធានដែលនៅក្នុងគុកនោះណា ...... គឺមកពីអាហុងនឹងណាដែលខ្ញុំនិយាយមកពីដំបូងនោះ ណា ។

ថ្វី៖ ហើយពេលហ្នឹងបងសឿងងនៅឯណាដែរ?

សឿ៖ ខ្ញុំនៅជាមួយហ្នឹងក្រុមគេដែលនៅខាងក្រៅនោះទេ ។

ថ្វី៖ តែពេលហ្នឹង តើបងសឿងងនៅឯណា?

សឿ៖ ខ្ញុំនៅជាមួយហ្នឹងគេដែរ នៅផ្ទះជាមួយគ្នា ។

ថ្វី៖ ពេលហ្នឹងយប់ឬថ្ងៃ?

សឿ៖ យប់ ។

ថ្វី៖ ប្រាប់ថាយ៉ាងម៉េច?

សឿ៖ ប្រាប់ថាមិត្តឯង បងឲ្យទៅបំពេញភារកិច្ចថ្មី ។

ថ្វី៖ ចឹងសឿងងនៅហ្នឹងដែរ?

សឿ៖ ចុះពេលហ្នឹងមិនទាន់ចេញយាមឯណា មិនទាន់ចេញដើរបាតខាងក្រៅផង ។

ថ្វី៖ យប់ម៉ោងប៉ុន្មាន?

សឿ៖ ម៉ោង៧យប់ ។

ថ្វី៖ កំពង់ធ្វើអីពេលហ្នឹង?

សឿ៖ កំពង់ប្រជុំជីវភាពតាមក្រុម ។

ថ្វី៖ ដល់ចឹងហ៊ុយមកទៅ?

សឿ៖ ដល់មកចឹងទៅថាមិត្តឯងបងឲ្យទៅបំពេញភារកិច្ច ។

ថ្វី៖ បងហ្នឹងនរណាគេ?

សឿ៖ បងហ្នឹងមានតែហ៊ុយហ្នឹងហើយ មាននរណាទៀតនៅហ្នឹង មានតែហូរហ្នឹងហ៊ុយហ្នឹងហើយ មានតែហ៊ុយ ហូរហ្នឹងហើយមានតែពីរ ហ្នឹងទេនៅហ្នឹងនោះ ។

ថ្វី៖ ហើយដល់ពេលហុងហ្នឹងបាត់ទៅមានពីរណាមកប្រាប់ឲ្យរើសមនុស្សថ្មីទេ?

សឿ៖ ហ៊ុយហ្នឹងគាត់មកទៀតគាត់ដូចថាមាននិរសាជំនិតដៃស្ដាំណាស់ ថាឥឡូវរើសប្រធានថ្មីទៅព្រោះហុងទៅបំពេលភារកិច្ចឆ្ងាយហើយ ចឹងគេតែងតាំងទៅ អើខ្ញុំឡើងបានមេក្រុមបីថ្ងៃដែរ ។

ថ្វី៖ ឡើងប្រធានក្រុម?

សឿ៖ ឡើងបានបីថ្ងៃដែលអត់ចេះអក្សរហ្នឹងគេ ។

ថ្វី៖ ឡើងធ្វើអីខ្លះ?

សឿ៖ គេគ្រាន់តែឲ្យប្រជុំជីវភាពទិទៀនអ្នកណាធ្វើខុសអ្នកណាធ្វើត្រូវ ស្ម័យទិទៀនអីហ្នឹងខ្ញុំអត់ចេះអក្សរខ្ញុំអត់ចេះនិយាយដូច គេទេ ។

ថ្វី៖ កាលហ្នឹងប៉ុន្មានថ្ងៃប្រជុំមួយដង?

សឿ៖ បីថ្ងៃប្រជុំមួយដងកាលហ្នឹង ។

ថ្វី៖ គេនិយាយពីអីខ្លះទៅ?

សឿ៖ គេប្រជុំថាកុំឲ្យដើរហើរអី កុំឲ្យមានខុសសីលធម៌ ប្រយត្ន័រួនប្រយត្ន័ចេញអីគឺមានតែប៉ុណ្ណឹង ។

ថ្វី៖ បងសឿងធ្លាប់ធ្វើជាប្រធានក្រុម តើនៅក្នុងមួយក្រុមមានប៉ុន្មាននាក់?

សឿ៖ មាន១២នាក់ ដល់តែគេដកមេមួយទៅនៅសល់តែ១១ ដល់តែគេដកមួយទៀតទៅតែមិនដឹងជាគេដកយកទៅណា នៅសល់តែ១០ទេ ដល់តែ៣-៤, ៥ថ្ងៃគេដកក្រុមនោះខ្លះទៅ គេចេះតែដកមួយក្រុមមួយៗទៅហើយចេះតែអស់ៗ ទៅតែមិនដឹងជាគេដកយកទៅណា ដល់តែអញ្ចឹងទៅគឺវាចេះតែឡូកឡំគ្នាទៅ បើថានៅជាមួយគ្នារហូតមានអីគឺនៅតែ ចេះតែចាំគ្នាហើយស្គាល់គ្នាបាត់ហើយ ដូចថានៅបាន៣-៤ ៥ថ្ងៃដកយកទៅបាត់ទៅ ឲ្យនៅទៅនៅឯណាមិនដឹងស្រាប់តែគេដកអាក្រុមនោះមកនៅជាមួយទៅ តើនរណាគេទៅស្គាល់គ្នាបើអត់ដែលស្គាល់គ្នាផង គឺនៅចាំគ្នាតែមួយភ្លែតៗ អញ្ចឹងបានតែថាវាពិបាកនិយាយរឿងរាយរាប់ប្រាប់ពីក្រុមណាស់ អានេះបើនិយាយទៅនៅក្នុងក្រុមគឺឃើញ ការដាក់ស្នែងគឺមានតែប៉ុណ្ណឹងណា ខ្ញុំប្រាប់អញ្ចឹងតែហ្នឹងទៅ បើថាពីក្រុមវិញគឺវាដកដូចនៅក្នុងថ្នុកល្មោនអញ្ចឹងឯង បានជាខ្ញុំប្រាប់បងថ្វីឯងហ្នឹងគឺមកពីវាមិនដែល តែបើថាគេឲ្យយើងកាន់នៅក្នុងក្រុមដូចជានៅសហករណ៍យើងនេះគឺវាគ្មានទេ គឺមួយថ្ងៃដកមួយថ្ងៃចេញ មួយថ្ងៃចូល ហើយអាអ្នកចូលមកទើបតែហ្នឹងស្គាល់គ្នាបានពីរថ្ងៃដកគ្នាទៅទៀតៗ អញ្ចឹងបានតែថាវាពិបាកអារឿងដកហ្នឹងណា ហើយបើថាសួរពីរឿងឈ្មោះគឺអត់មានស្គាល់ទេ បើថាស្គាល់គឺមានតែ ហ៊ុយហ្នឹងតែហ្នឹង ។

ថ្វី៖ ហ៊ុយហ្នឹងឈ្មោះពេញ ឈ្មោះអីដែរ?

សឿ៖ ទេ! ខ្ញុំអត់មានស្គាល់ឈ្មោះគេអ្នកធំៗទេ ខ្ញុំអត់មាននៅជិតអ្នកធំៗទេកាលហ្នឹង គឺមានស្គាល់តែឈ្មោះហ៊ុយហ្នឹងហើយ ក្រៅពីហ្នឹងគឺអត់មានស្គាល់ទេ ហើយបងហ៊ីប្រពន្ធគាត់ឈ្មោះមុតគាត់បានគ្នានៅក្នុងទទួលស្នែងជំនាន់ ប៉ុល ពត ហ្នឹង ដែរ ហើយបងឌុចនេះគឺគាត់មានកូនបីអ្នកតែមិនដឹងជាគាត់រៀបអីនៅឯណាទេខ្ញុំអត់ដឹងដែរ ។

ថ្វី៖ ពេលហ្នឹងមានធ្លាប់ឃើញប្រពន្ធគាត់នៅហ្នឹងដែរទេ?

សឿ៖ គាត់ស្នាក់នៅហ្នឹងទាំងអស់ហើយ បើគាត់ដើរមកហូបបាយនៅសហករណ៍ជាមួយកងទ័ពដែរ ។

ថ្មី: ប្រពន្ធគាត់រាងម៉េច?

សឿ: ប្រពន្ធគាត់រាងស្តើងហើយខ្មៅ តែមិនជាខ្មៅប៉ុន្មានទេ?

ថ្មី: ប្រពន្ធគាត់ឈ្មោះអី?

សឿ: ទេ! ខ្ញុំអត់មានហ៊ានសួរគេទេ សួរឈ្មោះប្រពន្ធកម្មាភិបាលកងពលនោះតើអ្នកណាទៅហ៊ានសួរ បើខ្លាចគេចង់ងាប់ ហើយមានអ្នកណាទៅហ៊ានសួរនោះ បើអត់ទាំងហ៊ានទៅអែបជាមួយហ្នឹងគេផងអ្នកណាទៅហ៊ានសួរឈ្មោះប្រពន្ធគេនោះ បើមួយម៉ាត់ដាច់ករមួយម៉ោកនោះ ។

ថ្មី: ហើយម៉េចបានជានាំគ្នាខ្លាចខុចខ្លាំងម្ល៉េះ ហើយអ៊ីដែលធ្វើឲ្យបងសឿឯងខ្លាចគាត់ខ្លាំងម្ល៉េះ?

សឿ: គេវាឃើញអាហ្នុំណា ឃើញអាខ្សែរក្លើងអានឆក់អាបែកហ្នឹងណា៎ ឃើញអាទៅបាត់ៗអញ្ចឹងណា បើថានៅនិយាយតទល់ជាមួយដូចជាបងឯងអញ្ចឹងស្មានតែថាខ្ញុំខ្លាច និយាយតទល់ជាមួយអញ្ចឹងបានស្មានតែខ្ញុំខ្លាច តែបើនិយាយជា មួយគាត់ហើយយប់ឡើងបាត់អញ្ចឹងល្អមុខគឺខ្ញុំខ្លាចនៅត្រង់ហ្នឹងតើ គឺមិនចាំបាច់វៃមិនចាំបាច់ដេរ គឺនៅចាំតែល្ងាចវា មកអូសក្បាលទៅតែម្តង ។

ថ្មី: កូនៗគាត់ប៉ុណ្ណាៗ កូនតាឌុច?

សឿ: អាបងគេកំពស់នេះ ។

ថ្មី: ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សឿ: ស្រីពីរប្រុសមួយ តែមិនដឹងជាងាប់ជារស់ទេពីព្រោះពេលដែលបែកហ្នឹងគឺខ្ញុំអត់បានដឹងដែរ ពីព្រោះគាត់រត់ទៅមុនខ្ញុំ ទៀត អ្នកធំៗគេរត់ទៅមុនពួកខ្ញុំទៀត ។

ថ្មី: បងសឿពីឆ្នាំ៧៥ - ៧៩
តើបងសឿឯងមានដែលឃើញអ្នកណាម្នាក់ទៀតធ្វើទារុណកម្មទៅលើមនុស្សម្នាក់ទៀតដោយសារតែមូលហេតុសាសនាដែលឬទេ ធ្វើបាបគេដោយសារតែគេកាន់សាសនាចាម សាសនាព្រះពុទ្ធអីចឹងណា?

សឿ: មានតែពួកអាពតហ្នឹង គឺមានតែឌុចហ្នឹងហើយដែលជាអាពត គឺមានតែឌុចហ្នឹងហើយគឺមិនថាចាមចិនអីទេ ឲ្យតែគាត់ចាប់បានគឺដឹងតែពីសម្លាប់ទាំងអស់ហ្នឹង ទោះជាពួកអាមេរិកកាំងក៏ដោយ អាហ្នឹងគឺមានតែឌុចហ្នឹងហើយដែលនៅក្នុងគុកទួលស្លែងហ្នឹងហើយ សួរអញ្ចឹងបានខ្ញុំដឹង តែបើថាសួរខ្ញុំច្រើនគឺខ្ញុំអត់មានចាំទេ គឺសួរខ្ញុំតាមវគ្គអញ្ចឹងបានខ្ញុំចាំ ។

ថ្មី: បងសឿឯងធ្លាប់ឃើញ នៅពេលដែលគេធ្វើបាបមនុស្សធ្វើទារុណកម្មមនុស្សអីដោយសារមូលហេតុសាសនា?

សឿ៖ ព្រោះតែពួកវាបំបាត់ព្រះពុទ្ធសាសនាហ្នឹងហើយបានជាពួកវាវៃនោះ បើថានៅគោរពសាសនាដូចជានៅរាល់ថ្ងៃនេះតើ មានអ្នកណាគេទៅហ៊ានវៃ ពីព្រោះនៅជំនាន់នោះហើយដែលពួកវាហ៊ានវៃ ហ៊ានសម្លាប់មិនថាអ្នកលល្អមិនថាអ្នកអាក្រក់ គឺមានបុណ្យមានទានឯណា ។

វីណា៖ មានឃើញផ្ទាល់ដូចថាម្នាក់ហ្នឹង ត្រូវគេចាប់យកទៅដោយសារកាន់សាសនា អីចឹងណាមានធ្លាប់ឃើញដែលទេ?

សឿ៖ អត់មានឃើញទេ អត់មានឃើញសាសនាណាជនជាតិណាទេ គឺឲ្យតែចូលគឺចាប់សូម្បីតែពួកអាមេរិកកាំងឲ្យតែចាប់បាន ដាក់ចូលទៅក្នុងហ្នឹងទាំងអស់ មិនថាសាសនាណាអីឯណាទេ មិនថាចាមមិនថាចិនយួនអីទេ ។

ថ្វី៖ បងសឿ ឯងធ្លាប់ឃើញនៅពេលណា ធ្លាប់ដឹងនៅពេលណាដែររឿងហ្នឹង ហើយនៅពេលហ្នឹងបងសឿឯងកំពុងតែធ្វើអី ហើយនៅកន្លែងណា?

សឿ៖ ខ្ញុំនៅយាមនៅខាងក្រៅគុកទួលស្លែងហ្នឹងហើយ ពីព្រោះអីក៏ឃើញមានយួនគេដឹកយកមកកន្លែងហ្នឹងដែរសម្លាប់នោ កន្លែងហ្នឹងដែរ ។

ថ្វី៖ បងសឿឯងបានឃើញផ្ទាល់ឬក៏លឺគេនិយាយ?

សឿ៖ រឿងហ្នឹងគឺខ្ញុំបានឃើញផ្ទាល់ ពីព្រោះខ្ញុំបានឃើញគេដាក់ឡានមកបានជាខ្ញុំថា គឺខ្ញុំឃើញដាក់ស្តែងការពិតរបស់ខ្ញុំបាន ជាខ្ញុំនិយាយ ។

ថ្វី៖ ឃើញនៅកន្លែងណាដែរបងសឿ?

សឿ៖ ឃើញនៅមាត់ច្រកចូលនៅលូរទឹកស្អុយ តែខ្ញុំមិនដឹងជានៅកន្លែងណា ឃើញឡានគេបត់ចូលពីច្រកគល់ស្ពានទៅទេណា ។

ថ្វី៖ ហើយម៉េចបានជាពូដឹងថាជាវៀតណាម?

សឿ៖ ចុះបើមួកគេក្រឡូសកូស បើខ្ញុំធ្លាប់ទៅវៃយួនដែរមិនស្គាល់ ។

ថ្វី៖ គេបាក់មួកគេ?

សឿ៖ បាុ! គេពាក់អាមួកផ្កាយគេ ។

ថ្វី៖ ចុះគេយកមកពីខាងណាដែរ?

សឿ៖ ទេ! អារឿងដែលគេយកមកពីខាងណាគឺខ្ញុំអត់មានដឹងទេ ដឹងតែយួនតែហ្នងឲ្យតែឃើញថាជាមួកហ្នឹងគឺដឹងតែថាយួនតែ ហ្នង ។

ថ្វី៖ ហើយក្រោយមកពួកហ្នឹងគេធ្វើម៉េចទៀត?

សឿ៖ មលដល់អញ្ជឹងទៅ គេដាក់ខ្នោះទៅណា ។

ថ្វី:	ក្រោយមកគេយកទៅណាដែរ?

សឿ:	មិនដឹងជាគេយកទៅកន្លែងណា គឺដូចជាខ្ញុំរៀបរាប់ពីដើមមកអញ្ចឹងគឺខ្ញុំអត់មានដឹង មិនដឹងជាគេយកទៅសម្លាប់នៅ កន្លែងណាគឺខ្ញុំអត់មានដឹងទេ ។

ថ្វី:	ក្រោយមកពួកហ្នឹងចេញពីគុកហ្នឹងអស់ទៅអញ្ចឹង?

សឿ:	គេចេញ ដូចខ្ញុំនិយាយថាបើគេចេញគឺនៅលើអាពោងណោះទេ ពីព្រោះគេជាអ្នកនៅយាមគុកនៅក្នុងហ្នឹង គឺអ្នកចូល ហើយហ្នឹងអ្នកចេញគឺនៅលើអាពោងណោះទេ អ្នកដែកនៅខាងក្រៅគឺគ្រាន់តែដើរយាមទេ ។

ថ្វី:	ពេលដែលយាមហ្នឹង តើបងសឿឯងមានបានឃើញអីខ្លះកើតឡើងដែលទេបងសឿ មានបានឃើញអីច្បាស់លាស់ ដែលទេបងសឿ?

សឿ:	គឺមានឃើញគេដាក់ខ្នោះតែប៉ុណ្ណឹង ឃើញតែគេដាក់ខ្នោះហើយបណ្ដើរចូលទៅគុកទេ គឺគ្រាន់តែឃើញប៉ុណ្ណឹងគឺយើងដើរ ចេញទៅបាត់ហើយ អត់មានហ៊ាននៅទៀតទេ អាហ្នឹងគឺខ្ញុំឃើញ ៣-៤ ៥ដងហើយគឺទាល់តែខ្ញុំចេញមកហ្នឹង ។

ថ្វី:	បងសឿឯងឃើញហ្នឹង តើពួកណាខ្លះទៅ?

សឿ:	ឃើញតែយួន ឃើញបូព៌ាយើងហ្នឹង ខ្មែរយើងហ្នឹងតែខ្ញុំវាមិនស្គាល់ ហើយក៏អត់មានបានដឹងហើយទៅសួរគេដែរ គឺគ្រាន់តែឃើញគេចង ឃើញតែម្ចូកអញ្ចឹងទៅគឺដឹងថាអានេះគឺជាពួកបូព៌ាអានេះជាពួកយួនអញ្ចឹងទៅ ។

ថ្វី:	គេមានដែលនិយាយប្រាប់បងសឿឯងថាមូលហេតុអីបានជាគេចាប់ពួកវៀតណាមហ្នឹងមកមូលហេតុអីបានជាគេចាប់ ពួកចាមហ្នឹងមកអី មានដែលលឺគេនិយាយអញ្ចឹងដែលទេ?

សឿ:	អត់ដឹងទេ អារឿងខូចខិលអីគឺអត់មានដឹងទេ ពីព្រោះយើងវាអត់បានដឹងហើយមិនសូវជាស្គាល់គេផង ។

ថ្វី:	អត់មានដែលធ្លាប់ស្គាល់អ្នកដែលគេចាប់មកដែលទេ?

សឿ:	អត់មានទេ ។

ថ្វី:	ដូចថាមានក្រុមបងសឿឯង ក្រុមគេផ្សេងៗទៀត?

សឿ:	អត់មានស្គាល់ទេ គឺមានតែអាពោមួយទេដែលគេដកពីក្រុមខ្ញុំទៅយាមនៅខាងក្នុងនោះ គឺមានតែអាពោមួយទេដែលគេ ដកពីក្រុមខ្ញុំដែលនៅខាងក្រៅនេះចូលទៅក្នុងមួយហ្នឹងទេ គេឲ្យចូលទៅមើលអ្នកគុកហ្នឹងណាគឺមានតែវាទេដែលបានចូល ទៅខាងក្នុងនោះ ។

ថ្វី:	អញ្ចឹងក្រុមបងសឿ ឯងគេដកបងពៅទៅ ឲ្យចូលទៅយាមនៅខាងក្នុង?

សឿ៖ បាទ! ។

ថ្វី៖ ចុះមានគេចាប់ក្រុមបងសៀងឯងអីទៅសម្លាប់ដែលទេ?

សឿ៖ គឺមានតែអាហុងបងអាពៅហ្នឹងមួយទេ ។

ថ្វី៖ គាត់ខុសអីដែលកាលហ្នឹង?

សឿ៖ ទេ! មិនដឹងជាខុសរឿងអីផង ខុសអារឿងទិទានគ្នាបន្តិចបន្តួច ។

ថ្វី៖ ចុះពេលដែលគេមកចាប់ហុងហ្នឹងទៅ តើគេមាននិយាយថាហុងហ្នឹងខុសអីដែលទេ?

សឿ៖ អត់ទេ គឺមានតែថាខុសគឺគេថាបញ្ជូនឲ្យទៅបំពេញភារកិច្ចថ្មីតែប៉ុណ្ណឹងទេ ។

ថ្វី៖ កាលហ្នឹងពីណាគេដែលថាមកដកឲ្យទៅបំពេញភារកិច្ចថ្មី?

សឿ៖ បងប៉េង បងប៉េងហ្នឹងសូម្បីតែបងគាត់បងវ៉ាន់ហ្នឹងក៏នេះដែរណា ។

ថ្វី៖ ពីណាគេខ្លះទៀតដែលបានដឹងរឿងថាបងហុងហ្នឹងត្រូវបានគេចាប់ទៅ?

សឿ៖ ទេ! អត់មានពីណាគេដឹងផងបើគេថាទៅបំពេញភារកិច្ចថ្មី ទាល់តែអាពៅវាចូលទៅយាមបានឃើញបងវា ហើយគឺដឹង តែគេថាបញ្ជូនទៅឯណេះទៅឯណោះហ្នឹងណា កងទ័ពដឹងស្រាប់ហើយគេម៉ោងណាគឺស្រេចតែគេ ។

ថ្វី៖ អញ្ចឹងនៅពេលដែលបងពៅមកប្រាប់បងសឿ ឯង បានបងសៀងឯងដឹងថាហុងជាប់គុក?

សឿ៖ បាទ! ។

ថ្វី៖ អញ្ចឹងបានន័យថាភារកិច្ចថ្មីរបស់គេហ្នឹងម៉េចដែរ?

សឿ៖ គឺជាប់គុក គឺមានយកទៅកាន់ក្ដាប់នៅឯណាឯណីណា គឺយកទៅដាក់គុក ។

ថ្វី៖ ចុះអារឿងដែលយកទៅធ្វើភារកិច្ចថ្មីហ្នឹង តើមានអ្នកផ្សេងទៀតដែលគេយកទៅហើយគេប្រាប់ថាយកទៅបំពេញភារ កិច្ចថ្មីទៀតដែលទេ?

សឿ៖ បើទៅបំពេញភារកិច្ចផ្សេងគឺមាន គឺគេដកយកទៅឲ្យគាស់គល់លត់ដីដល់ម៉ោង១២, ម៉ោង១អីនៅព្រៃសរមិនទាន់បាន មកស៊ីផង គេអត់មានឲ្យស៊ីបាយទេអាហ្នឹងកងទ័ព ។

ថ្វី៖ តើបងពៅឯងមានដែលឃើញអ្នកណាម្នាក់បំផ្លាញវប្បធម៌ឬក៏ស្នាដៃសិល្បៈអីដែលទេ?

សឿ៖ អត់ដែលឃើញទេ គឺអត់មានដឹងហ្នង ។

ថ្វី៖ មានដែលលឺគេនិយាយពីរឿងហ្នឹងដែលទេ?

សឿ៖ អត់ទេ អត់មានដែលលឺទេ ។

ថ្វី៖ អត់មានដែលឃើញអ្នកណាម្នាក់វៃអ្នកល្មោនអីទេ?

សឿ៖ អត់ទេ តែបើថាអារឿងវៃរឿងអីគឺខ្ញុំអត់ដឹងដែរ ពីព្រោះអត់ឃើញ ។

ថ្វី៖ អត់មានដែលឃើញគេចាប់មកទួលស្លែងអីទេ?

សឿ៖ អត់ទេ គេអត់មានដែលប្រាប់ថាតួរកុនតួរល្ខោនអីទេ បើគេមិនដែលប្រាប់យើងផង តើអ្នកណាទៅដឹង ។

ថ្វី៖ ចុះពូមានដែលស្គាល់អ្នកចំរៀងល្បីៗដែលទេ?

សឿ៖ អត់ស្គាល់ទេ ។

ថ្វី៖ មានដែលឃើញគេបំផ្លាញវត្តអីទេ?

សឿ៖ អត់មានដែលឃើញទេ ហើយខាងកងទ័ពខ្ញុំក៏អត់មានដែលបានចេញទៅក្រៅដែរ បើអ្នកដែលនៅខាងក្រោយនៅតាម សហករណ៍អីដែលនៅខាងក្រោយ អ្នកដែលគេសម្លាប់ឪពុកម្តាយខ្ញុំអីអាហ្នឹងគឺមានប្រវត្ត គឺមានអ្នកដែលនៅរស់នៅ គគោក ។

ថ្វី៖ ចុះវិហារអ៊ីស្លាមអីមានដែលឃើញដែលទេ?

សឿ៖ ថាខ្ញុំអត់ស្គាល់ទេ គឺពេលដែលទៅនៅខាងហ្នង់គឺអត់មានដែលវិហារអ៊ីស្លាមអីទេ ពេលដែលមកដល់ភ្នំពេញគឺខ្ញុំអត់មាន ស្គាល់វត្តផង ខ្ញុំថាតែផ្ទះថ្មទាំងអស់ផង ។

ថ្វី៖ ចុះបងសឿឯងនៅភ្នំពេញដែលតើ ម៉េចបានជាអត់ស្គាល់វត្ត?

សឿ៖ ចុះមកនៅភ្នំពេញគឺទើបតែហ្នឹងចេញពីនោះមក មានដែលទៅស្គាល់វិហារចាមឯណា បើទៅត្រង់ណាក៏កំពូលៗ បើនៅយូរទៅគ្រាន់ស្គាល់ តែបើទើបតែហ្នឹងមកបានមិនទាន់បានស្គាល់គ្រប់ជ្រុងជ្រោយផង ។

ថ្វី៖ អញ្ចឹងបងសឿឯងដឹងតែពីរឿងដែលគេសម្លាប់មនុស្សនៅក្នុងគុកទួលស្លែងហ្នឹងតែហ្នង?

សឿ៖ បាទ! គឺខ្ញុំដឹងតែពីរឿងដែលគេសម្លាប់មនុស្សនៅក្នុងគុកទួលស្លែងហ្នឹង ចុះបើខ្ញុំជាអ្នកយាមនៅខាងក្រៅឃើញតែគេចាប់ មកអញ្ចឹង ចូលទៅក្នុងគុកទួលស្លែងគឺខ្ញុំបានឃើញជាក់ស្តែង ។

ថ្វី៖ តែអត់មានដែលបានឃើញគេសម្លាប់មនុស្សនៅក្នុងទួលស្លែងហ្នឹងទេ?

សឿ៖ អត់មានឃើញទេ គេសម្លាប់នៅក្នុងហ្នង់ក៏យើងមិនដឹង គេមិនសម្លាប់នៅក្នុងហ្នឹងក៏យើងមិនដឹងដែរ ។

ថ្វី៖ ចុះអត់មានដែលបានចូលទៅក្នុងទេអញ្ចឹង?

សឿ៖ អ! ចូលទៅអត់បានទេ ។

ថ្វី៖ ចុះអត់មានដែលលឺអ្នកយាមគ្នាឯងអី គេនិយាយថាមានការសម្លាប់មនុស្សនៅក្នុងគុកទួលស្លែងអីមានដែលលឺទេ?

សឿៈ អត់មានទេ អាពៅអ្នកយាមនៅក្នុងនោះក៏មានដែលបានឃើញគេសម្លាប់នៅក្នុងនោះដែរ គឺមានតែដឹកឡានចេញទៅ ខាងក្រៅ ។

ទ្រីៈ គេដឹកទៅហ្នឹង តើគេដឹកចេញទៅណា?

សឿៈ ទាល់តែអាពៅបានវាដឹង ។

ទ្រីៈ អត់ទេ តែបងសឿងឯងមានដឹងថានៅពេលដែលគេដឹកចេញទៅហ្នឹង តើគេដឹកយកទៅកន្លែងណា?

សឿៈ ទៅអន្លង់ខ្ញែកអីទេ ដូចជានៅអីដើងឯកគេនោះ ។

ទ្រីៈ តែអានៅពេលដែលគេធ្វើទារុណកម្មអីណាបងសឿ តើមានដល់ថ្នាក់ស្លាប់ដែលទេនៅពេលដែលគេសួរចម្លើយអីនោះ?

សឿៈ ពួកខ្ញុំនៅខាងក្រៅគឺអត់មានដែលឃើញទេ តែមានគ្នាឯងប្រាប់ វាថាវៃគ្នាដល់ហើយឆក់ខ្សែភ្លើង អាណាគេត្រង់ ឆ្លើយទៅឆ្លេងអស់ហើយអត់មានដឹងអីទេ ។

ទ្រីៈ បងសឿងឯងមានដែលដឹងថា មានគេរំលោភអ្នកទោសស្រីៗ នៅក្នុងគុកហ្នឹងដែលទេ?

សឿៈ ខ្ញុំថាអត់ដឹងៗ គឺអត់ដឹងហើយទាល់តែគេអ្នកដែលនៅក្នុងហ្នង់ហ្នងបានគេដឹង ។

ទ្រីៈ អញ្ចឹងគឺគ្រាន់តែមានគេដឹង?

សឿៈ បាទ! ពីព្រោះគេជាអ្នកយាមនៅក្នុងគឺគេដឹង ប៉ុនបើថានៅផ្នែកខាងខ្ញុំគឺអត់មានដឹងទេ ប៉ុនពេលដែលគេហៅខ្ញុំទៅសួរហ្នឹង គឺខ្ញុំបានដឹងតាមឯកសារថាអ្នកទោសហ្នឹងក៏មានដែរ តែពេលដែលគេសួរខ្ញុំគឺខ្ញុំអត់ដឹងទាំងអស់ ។

ទ្រីៈ ចុះអត់មានដែលលឺគ្នាឯងដែលជាអ្នកយាមនិយាយថា អូរ!មានឃើញគេរំលោភអ្នកទោសអី?

សឿៈ ហើយក្រៅពីហ្នឹងគឺអត់ មាន ពីណាគេដឹងទេ គឺទើបតែដឹងនៅពេលឥឡូវនេះទេ ទើបតែគេមកសួរចម្លើយការពិតនេះទេ ហ៊ឺ!បើចិនជាហ៊ានទៅសួរនៅ កាលនោះគឺឆាប់បាត់ហើយ បើគ្រាន់តែនិយាយគ្នាមិនបានផង............... អាប្រឹកបានវាដឹងពី ព្រោះវាជាអ្នកឆក់ខ្សែរ ភ្លើងអីអាហ្នឹងបានវាជាអ្នកដឹង គេជាអ្នកវៃអន្តុលីលេខបានគេដឹងពីព្រោះ ជាគេជាអ្នកវៃឈ្មោះអ្នកទោសចេញអ្នកទោសចូល ពេលដែលគើសួរវាមិននៅអន្តុយវៃនៅកន្លែងហ្នង់ អាហ្នឹងមិនអញ្ចឹង គេជាអ្នកវៃឯកសារ អ្នកទោសអីគេមិនអន្តុយនៅអមអ្នកដែលគេសួរចម្លើយ ហើយអត់ឆ្លើយគ្រាន់តែប៉ុណ្ណឹងខ្លាចឆាប់ដែរ ចុះកាលនៅជំនាន់នោះ មិនខ្លាចឆាប់ ផង

ទ្រីៈ ចុះបងសឿងឯងខ្លាចឆាប់ដែលទេ?

សឿៈ អត់ខ្លាចទេ លែងខ្លាចឆាប់ហើយអាយុប៉ុណ្ណេះហើយចូលហារហើយ ។

ថ្វីៈ បងសឿនៅពេលបន្តិចទៀតនេះ ខាងរដ្ឋាភិបាលខ្មែរយើងហើយហ្នឹងអង្គការសហប្រជាជាតិ គេបំរុងបង្កើតតុលាការមួយ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម តើបងសឿឯង មានដែលលឺដំណឹងពីរឿងហ្នឹងដែលទេ?

សឿៈ លឺយូរដែរហើយ ប៉ុន្តែខ្ញុំភ្លេចហើយ ។

ថ្វីៈ លឺគេនិយាយថាម៉េចខ្លះ?

សឿៈ លឺគេកាត់ទោសមេខ្មែរក្រហម តែខ្ញុំមិនសូវចាំធ្លាប់លឺតាមប៉ុសវ៉ាដ្យូដែរ ។

ថ្វីៈ ហើយបងសឿយល់ថាការបង្កើតឲ្យមានតុលាការហ្នឹង តើវាមានប្រយោជន៍ដែរអត់?

សឿៈ ខ្ញុំមិនហ៊ានថាដែរ តែឲ្យតែគេបង្កើតឲ្យមានតុលាការតើវាមានប្រយោជន៍ហើយ ។

ថ្វីៈ តើវាមានប្រយោជន៍អីខ្លះទៅបងសឿ នៅពេលដែលយើងបង្កើតឲ្យមានតុលាការកាត់ទោស ខ្មែរក្រហម?

សឿៈ ប្រយោជន៍ដល់ប្រទេសជាតិ មិនមានអ្នកខូចអ្នកណាអាក្រក់ អត់មានពីណាក្បត់ ។

ថ្វីៈ ចុះពីណាគេខ្លះដែលជាមេដឹកនាំខ្មែរក្រហមធំៗ?

សឿៈ ខ្ញុំអត់ស្គាល់ទេ លឺតែឈ្មោះតែយើងមិនស្គាល់ ។

ថ្វីៈ មានឈ្មោះអីខ្លះ?

សឿៈ មេដំបូងតាម៉ុក, សុន សេន, ខៀវ សំផន, នួន ជា, ហ៊ូ នឹម. តែអ្នកទាំងអស់ហ្នឹងគឺលឺតែ ឈ្មោះទេតែមិនដែលបាន ឃើញមុខទេ ហើយម៉ៅសេតុងអីនោះអាហ្នឹងគេជាអ្នកដែលមកពី ចិន ។

ថ្វីៈ ហើយបងសឿនៅពេលដែលមានតុលាការអញ្ចឹង ហើយអ្នកដែលជាខ្មែរក្រហមនៅខាងក្រោម ៗអញ្ចឹងតុលាការគេអត់ មានកាត់ទោសទេ តើបងសឿយល់ថាគេធ្វើអញ្ចឹងតើវាត្រឹមត្រូវ ដែលទេ?

សឿៈ អត់ត្រឹមត្រូវទេ បើថាកាត់ទោសមេធំៗគឺត្រូវកាត់ទោសអាអ្នកដែលនៅតាមសហករណ៍នេះ ដូចជាអាមីអាអីនេះ ដែលពួកវាជាអ្នកសម្លាប់ឪពុកម្តាយខ្ញុំ គឺត្រូវប្រមូលឯកសារឲ្យអស់ ពីព្រោះប្រជាជនដែលគេប្រាប់ខ្ញុំថាដូចជាអាឃី, អាយេងអីនេះគឺនៅបាត់ដំបង គឺពួកអាហ្នឹង ហើយដែលជាអ្នកសម្លាប់នៅតាមសហករណ៍រាប់ម៉ឺនរាប់សែននោះ ។

ថ្វីៈ អញ្ចឹងបានន័យថាបងសឿ ឯងចង់ឲ្យគេកាត់ទោសកូនទាហានខ្មែរក្រហមដែលនៅតាមភូមិ ឃុំទៀត?

សឿៈ គឺឲ្យវាមកទាំងអស់អញ្ចឹងតែម្តង បើថាអត់កាត់គឺអត់កាត់ទាំងអស់តែម្តង ។

ថ្វីៈ អញ្ចឹងបើកាត់គឺកាត់ទាំងអស់ បើអត់គឺអត់ទាំងអស់?

សឿៈ បើថាអត់គឺអត់ទាំងអស់ ។

ថ្វីៈ ចុះបងសឿឯងធ្វើជាខ្មែរក្រហមដែរនោះ?

សឿៈ ខ្ញុំធ្វើជាខ្មែរក្រហមគឺកាត់ទាំងខ្ញុំទៀតទៅ គឺថាអ្នកដែលជាប់ជាអាពតទាំងប៉ុន្មានគឺត្រូវកាត់ទាំងអស់ ។

ថ្វីៈ ម៉េចបានជាធ្វើអញ្ចឹងបងសឿ?

សឿៈ សូម្បីតែ ហ៊ុន សែន ក៏ខ្ញុំឲ្យកាត់ពីព្រោះគាត់ធ្វើជាខ្មែរក្រហមដែរ ។

ថ្វីៈ ចុះអាហ្នឹងបើគេកាត់ទាំងអស់ទៅ តើបងសឿឯងយល់ថាម៉េចដែរ?

សឿៈ អាហ្នឹងគឺវាសមស្រប ។

ថ្វីៈ អញ្ចឹងបានន័យថាអ្នកទាំងអស់គ្នាគឺសុទ្ធតែមានកំហុសអញ្ចឹង?

សឿៈ ពីព្រោះជាប់ប្រវត្តទាំងអស់ហើយ ។

ថ្វីៈ ជាប់ជាប្រវត្តប៉ុន្តែគេ.....?

សឿៈ ឲ្យតែជាប់ប្រវត្តអាពតហើយ
គឺថាឲ្យតែមេខុសហើយគឺត្រូវតែពួកអាកូនទៅតាមដែរតាមខ្សែបណ្តាញ បើថាកាត់ទោសតែមេណាម្នាក់ដែលសម្លាប់គេ អាហ្នឹងគឺខ្ញុំឯកភាព បើសិនជាអ្នកដែលមិនបានសម្លាប់ក៏ជាប ' ហើយអាអ្នកដែល សម្លាប់គេហើយក៏អត់ជាប់អាហ្នឹងគឺខ្ញុំវាតូចចិត្តទៅវិញ ។

ថ្វីៈ តែតុលាការគេចង់តែកាត់ទោសមេខ្មែរក្រហម៥-៦នាក់នៅខាងលើ ដែលជាអ្នកធំៗទេ?

សឿៈ អាហ្នឹងគឺថ្នាក់ច្បាប់ គឺគេកាត់ទៅក៏តាមថ្នាក់ច្បាប់ ហើយអារឿងដែលគេថាកាត់ហ្នឹងគឺគេប្រុងកាត់យូរហើយ នៅតែកាត់ៗនេះ....... ហើយអាកាត់នេះខ្ញុំឈ្លោះជាមួយហ្នឹងប្រពន្ធខ្ញុំហើយ ទៅវ៉ៃគេឯណោះទៅ ទៅវ៉ៃគេវានៅល្អតែ ប្រពន្ធខ្ញុំដដែលទេមើលទៅ គឺខ្ញុំនឹកឃើញតែប៉ុណ្ណឹងទេ ។

ថ្វីៈ ចុះឧបមារថានៅពេលដែលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយបងសឿឯងធ្លាប់ធ្វើជាអ្នកយាមអីនៅទួលស្លែង ហើយបើគេចង់ឲ្យបងសឿ ឯងទៅនិយាយប្រាប់ពីរឿងរ៉ាវដូចដែលបងសឿឯងនិយាយប្រាប់ខ្ញុំហ្នឹង តើបង សឿឯងអាចទៅនិយាយប្រាប់តុលាការបានដែលអត់?

សឿៈ រឿងឯកភាពគឺឲ្យតែប្រមូលក្នុងឯកសារអ្នកដែលនៅទួលស្លែងទាំងអស់ ។

ថ្វី៖ តែសំនួរគេសួរថាតើបងសឿងឯងហ៊ានទៅដែរអត់ ទៅនៅពេលហ្នឹងគឺទៅនិយាយប្រាប់តុលាការ?

សឿ៖ ប៉ុន្តែបើថាទៅតែខ្ញុំគឺមិនមែនធ្វើតែខ្ញុំទេណា៎ គឺត្រូវតែទៅទាំងអស់គ្នាសួរចម្លើយទាំងអស់គ្នា ។

ថ្វី៖ ហើយពីណាគេខ្លះដែលបងសឿ ឯងថាឲ្យទៅដែរនោះ?

សឿ៖ ចុះដូចជាហ៊ុយ អីនោះប្រមូលឲ្យទៅទាំងអស់ ។

ថ្វី៖ តែនេះទៅគេហៅទាំងអស់ហ្នឹង តែបងសឿឯងហ៊ានទៅដែលអត់?

សឿ៖ ខ្ញុំទៅ ។

ថ្វី៖ ពេលទៅដល់ហ្នឹង?

សឿ៖ គឺឆ្លើយតាមពាក្យរបស់ខ្ញុំ បើថាត្រូវតែកាត់គឺត្រូវតែកាត់ ។

ថ្វី៖ តែនៅពេលនោះគឺខ្ញុំចង់ឲ្យបងសឿងឯងទៅធ្វើជាសាក្សីនិយាយប្រាប់គេណា ដូចបងសឿ ឯងនិយាយប្រាប់ខ្ញុំអញ្ចឹងថា ស្អីដែលបងសឿងឯងបានឃើញ ហ្នឹងអ៊ីដែលបងសឿងឯងបានលឺពីព្រោះបងសឿងឯងជាអ្នកដែលធ្លាប់ធ្វើការនៅហ្នឹង បានដឹងយល់ទេបងសឿ ហើយតុលាការគេចង់ស្នើរឲ្យអញ្ជើញបងសឿទៅតុលាការហើយនិយាយប្រាប់ ដូចតែបង សឿងឯងនិយាយប្រាប់ខ្ញុំអញ្ចឹង ហ៊ានដែលទេ?

សឿ៖ គ្រាប់មិនទាំងខ្លាចផង ទៅខ្លាចអីអាត្រឹមនិយាយ ។

ថ្វី៖ បងកាលពីមុននៅឆ្នាំ៨០ គេបង្កើតតុលាការឲ្យកាត់ទោសម្តងដែរ ដែលគេហៅថាកាត់ទោស ប៉ុល ពត .អៀង សារី អីនោះតើបងសឿងឯងមានដែលធ្លាប់លឺដែលទេ?

សឿ៖ អត់ដែលលឺទេ ពីព្រោះពាក្យណាដែលខ្ញុំអត់ចាំអត់បានលឺគឺខ្ញុំអត់និយាយទាំងអស់ ពីព្រោះខ្លាចនិយាយទៅវាខុសពាក្យ ខុសអី អារឿងណាដែលខ្ញុំអត់ចាំគឺខ្ញុំអត់និយាយទេ ។

ថ្វី៖ អញ្ចឹងរឿងតុលាការពីមុនមកគឺអត់មានដែលបានលឺទេ?

សឿ៖ លឺដែរ! ប៉ុន្តែយើងវាអត់ព្យាយាមស្តាប់ ខ្លះអីវិទ្យុគេផ្សាយលឺរាល់ថ្ងៃតែយើងវាអត់បានទៅព្យាយាមស្តាប់ គឺយើងគិតតែពីការងាររបស់យើងផ្សេង ហើយអាការងារនោះគឺនៅចាំតែថានៅថ្ងៃណាគឺនៅថ្ងៃហ្នឹងទៅ ។

ថ្វី៖ បងសឿខបមារថានៅពេលដែលមានតុលាការអីហើយគេកាត់ទោសអីហើយ តើបងសឿងឯងយល់ថាតុលាការហ្នឹងវា អាចធ្វើឲ្យអ្នកដែលមានបងប្អូនស្លាប់មានម្តាយស្លាប់អាចស្ងប់ចិត្តដែលទេ ហើយសប្បាយចិត្តឡើងវិញដែលទេលែងខឹង លែងសម្បារអី?

សឿ៖ វាល្អដែរ ។

ទ្រី៖ បងសឿងយល់ថាអញ្ចឹងដែរ?

សឿ៖ ខ្ញុំយល់ថាអញ្ចឹងដែរ ។

ទ្រី៖ ហេតុអីបានជាបងសឿងយល់ថាអញ្ចឹងដែរ?

សឿ៖ ដូចថាវាលែងខឹងលែងសម្បារ ប៉ុន្តែខ្ញុំទាល់តែយកអាអ្នកសម្លាប់ឪពុកខ្ញុំមកដែរបានខ្ញុំលែងខឹង ។

ទ្រី៖ ចង់ឲ្យគេរកអ្នកដែលសម្លាប់ឪពុកបងសឿងមកដែរ?

សឿ៖ បាទ៎! ។

ទ្រី៖ អញ្ចឹងគេអ្នកដែលបងប្អូនដែលស្លាប់នៅទួលស្លែងនោះ គេមិនចង់សួរដូចបងសឿងដែរ?

សឿ៖ គេចង់សួររកដែរ ។

ទ្រី៖ អញ្ចឹងបានតែថាតុលាការដែលគេបង្កើតនៅថ្ងៃខាងមុខនេះ គឺគេចង់កាត់ទោសតែមេ៥-៦នាក់ដែលធំៗទេ ហើយអ្នក ដែលគេសម្លាប់ឪពុកបងសឿងនោះ ស្មារទោសគឺក៏អត់យកមកកាត់ទោសដែរ តើបងសឿងយល់ថាម៉េចដែរ?

សឿ៖ អញ្ចឹងបើកាត់ទោសសម្លាប់តែអាធំៗក៏ខ្ញុំឯកភាព ពីព្រោះបញ្ជារគឺបញ្ជារពីអាធំៗមកបានអាតូចធ្វើ មិនអញ្ចឹង ប៉ុនតែ អាធំហ្នឹងវាមិនដឹងជាធំណា៎ វាអញ្ចេះទៅទៀត ។

ទ្រី៖ វាមិនដឹងជាអាធំណាហ្នឹងបានជាគេកំពង់តែរក ថាតើអាំណាដែលជាអ្នកធ្វើ ឧបមារថាបើរកឃើញថាអាធំហ្នឹងមាន ទោសត្រូវតែទទួលខុសត្រូវ តើបងសឿងចង់ឲ្យមានការបន្ធូរបន្ថយទោសឬក៏ចង់លើកលែងទោសឲ្យពួកហ្នឹងដែលទេ?

សឿ៖ អាហ្នឹងរឿងចំណែកខ្ញុំតាមចិត្តរឿងរបស់ខ្ញុំ អើបើថាអ្នកធំផ្សេងៗដែលខ្ញុំអត់បានឃើញធ្វើជាឃាដករ នៅចំពោះមុខ ខ្ញុំសុខចិត្តបន្ធូរបន្ថយចុះ បើថាធ្លាប់ឃើញដូចជាតាឌុច តាអីគឺខ្ញុំសុខចិត្តឲ្យគេកាត់ទោសទៅតាមច្បាប់អស់មួយជីវិតតែម្តងទៅ ។

ទ្រី៖ អត់មានចង់បន្ធូរបន្ថយទោសអីទេ?

សឿ៖ អត់មានបន្ធូរទេ ។

ទ្រី៖ តែបើអ្នកដែលិនដែលឃើញ?

សឿ៖ អ្នកដែលមិនដែលឃើញច្បាស់អាហ្នឹងគឺខ្ញុំអាចលើកលែងទោស
ប៉ុនតែអារឿងដែលបញ្ជារដាក់មកគឺខ្ញុំមិនដឹង មិនបាន ឃើញដាក់ស្តែង ។

ទ្រី៖ ម៉េចបានជាបងសឿងដូចជាខឹងឌុចខ្លាំងម្ល៉េះ មិនបន្ធូរបន្ថយទោសឲ្យហើយអ្នកផ្សេងម៉េចបានជាបន្ថយទោសឲ្យ ម៉េច បានទៅជាអញ្ចឹង ស្អីខ្លះដែលធ្វើឲ្យបងសឿងទៅជាអញ្ចឹង?

សឿៈ ពីព្រោះគាត់អត់យល់ខ្មែរ អត់យល់កូនចៅដែលនៅជាមួយគ្នា ដែលនៅការពារហើយ អញ្ចេះ អញ្ចុះ គាត់ប្រទះនៅត្រង់ ណាប៉ះជើងដាក់ជើងប៉ះដៃដាក់ដៃ បាយបើថាឲ្យត្រូវស៊ីបានស៊ី ម៉ោង១១-១២អីទល់តែមួយអី កង់ទ័ពជូនអត់ឲ្យស៊ី ដែរ តើបានអីទៀត ។

ថ្មីៈ បងសឿមិញ បងសឿឯងធ្លាប់និយាយថាអ្នកដែលធ្លាប់សម្លាប់បងសឿឯង ឧបមារថាបើ បងសឿឯងបានឃើញបាន ដឹង តើបងសឿឯងធ្វើម៉េចទៅ?

សឿៈ ខ្ញុំវានឹកឃើញថាដែលនៅរស់ពីនោះទាំងអស់គ្នា ហើយសព្វថ្ងៃខ្ញុំនឹកឃើញថាឈាមវាលែង សងឈាម បើសិនជានៅនឹក គ្នាថាគំនុំឈាមសងឈាមនេះ ក៏វាអត់រួចពីដៃខ្ញុំដែរ មនុស្ស មកពីនោះរួចផុតទាំងអស់គ្នាហើយគឺត្រូវយើងសាមគ្គីរស់ ទាំងអស់គ្នាទៅ ហៅគ្នាជាការធម្មតា រាប់គ្នាអីជាការធម្មតា ហើយគំនុំហ្នឹងគឺត្រូវតែបន្ធូរបន្ថយ ។

ថ្មីៈ ចុះបងសឿឯងមានគិតថាចង់ឲ្យពួកហ្នឹងមកសុំទោស ថាហ្អូកខ្ញុំខុសហើយដែលខ្ញុំធ្វើអញ្ចឹង ហើយឥឡូវខ្ញុំមកសុំទោស?

សឿៈ តែខ្ញុំអត់ចង់ឲ្យមកជួបមុខទេ ពីព្រោះខ្ញុំខ្ពិលណាស់ ។

ថ្មីៈ ម៉េចចឹង?

សឿៈ វាខ្មាស់គេទៀតណា ។

ថ្មីៈ បងសឿឧបមារថាបងសឿឯងស្គាល់ឈ្មោះក ហើយម្នាក់កហ្នឹងជាអ្នកដែលធ្វើបាបឪពុកម្តាយ ឪពុកឯង តើបងសឿ ឯងចង់ជួបមុខម្នាក់ហ្នឹងដែលអត់ ចង់ឲ្យម្នាក់ហ្នឹងមកសុំទោសបង សឿ ឯងដែលអត់?

សឿៈ ទេ! នៅឆ្ងាយណាស់ រត់បាត់ហើយ ។

ថ្មីៈ ឧបមារថានៅរស់ក្នុងភូមិអីណា?

សឿៈ នៅក្នុងភូមិនេះ តែរត់បាត់ហើយ អត់មានហ៊ាននៅទេ ។

ថ្មីៈ ចុះឧបមារថាគេមកវិញ?

សឿៈ អត់មកទេ មកបានមួយយប់រត់បាត់ទៀតហើយ ។

ថ្មីៈ ចុអឥឡូវឧបមារថាស្អែកមក ហើយគេនៅរហូត តើបងសឿឯងចង់ជួបមុខគេដែលអត់?

សឿៈ ទេ! អត់ចង់ទេ ។

ថ្មីៈ ម៉េចអញ្ចឹង?

សឿៈ ពីព្រោះឃើញមុខរួចហើយ អត់ចង់ទេ ។

ថ្មីៈ ចុះយ៉ាងម៉េចបានជាអត់ចង់?

សឿៈ គឺលែងយ៉ាងម៉េចគឺអត់ចង់អញ្ចឹងហ្នឹង ខ្ញុំអត់ចង់ទេ ។

ទ្រីៈ អត់ចង់ឃើញមុខទៀត?

សឿៈ អត់ចង់ឃើញហ្នឹង ។

ទ្រីៈ ម៉េចអញ្ចឹង?

សឿៈ ថាស្អប់គឺស្អប់តែហ្នឹង តែហៅគឺនៅតែហៅ និយាយគឺនៅតែនិយាយ បើហៅបាយអីឲ្យហូបគឺនៅតែហូប ប៉ុនមិនធ្វើហូប ។

ទ្រីៈ គេហៅឲ្យទៅហូបបាយ បងសឿឯងទៅហូប?

សឿៈ អត់ទេ! ខ្ញុំហៅគេមកហូបបាយគឺត្រូវតែហូប តែខ្ញុំអត់មានធ្វើបាបគេ ចិត្តខ្ញុំនៅក្នុងពោះគឺថារាប់អានគ្នាធម្មតា ហើយអ្នកដែលស្លាប់ទុកឲ្យស្លាប់ទៅចុះ អ្នកដែលនៅរស់ទុកឲ្យរាប់អានគ្នាវិញ ។

ទ្រីៈ អញ្ចឹងបងសឿឯងអត់មានគុំគេនៅក្នុងចិត្តទេហ្ន៎?

សឿៈ អត់ទេ អត់មានទេ..................... ។

ទ្រីៈ បងសឿឯងបងយល់ថាសាសនាយើង តើសាសនាយើងនៅក្នុងចំនុចណាដែលអប់រំ បងសឿឯងឈប់ខឹងពួកហ្នឹងបាន តើការឈប់ខឹងបងសឿឯង តើមានចំណែកមកពីសាសនាទេដែលធ្វើឲ្យបងសឿឯងឈប់ខឹងបាន?

សឿៈ ទេ! មិនថាសាសនា ពុទ្ធសាសណាក៏ដោយឲ្យតែរួបរួមគ្នាសាមគ្គីគ្នា ដើម្បីធ្វើបុណ្យធ្វើទានតែបើថាចំណែកខ្ញុំគឺថាដោយ សារតែចិត្តរបស់ខ្ញុំទៅ ហើយបើថានៅក្នុងព្រះពុទ្ធសាសនា បើថាត្រូវធ្វើគឺធ្វើ បើថាមិនត្រូវធ្វើគឺមិនធ្វើតែហ្នឹង ។

ទ្រីៈ បងសឿឯងមានដែលដឹងរឿងសាសនាដែលទេ?

សឿៈ ទេ! ខ្ញុំមិនសូវជាដឹងដែរ អត់សូវចេះទេ អារឿងព្រះពុទ្ធសាសនា ប៉ុនតែថាឲ្យខ្ញុំដឹងគឺខ្ញុំដឹងគឺខ្ញុំយល់ចិត្តរបស់ខ្ញុំហ្នឹង ...ក្តៅណាស់ ។

ទ្រីៈ បងសឿ បងសឿឯងលើកមើលតើសាសនាយើងមានចំនុចអីខ្លះ ដែលបងសឿគិតថាល្អសាសនាយើងល្អចំនុចអីខ្លះ?

សឿៈ សាសនាខ្មែរ ជួនណាមានកំដែងប្រឡំ ខ្ញុំស្តាប់នៅក្នុងវ៉ាដ្យូ ជួនកាលធ្វើលោកកោរសក់ទៅបោកគេទៅប្លន់គេក៏មាន ព្រះពុទ្ធសាសនាណាដែលចូលមក ហើយលុយកាក់ទៅបំភ្លេចព្រះពុទ្ធសាសនាក៏មាន វាអញ្ចឹងបានតែថាវាពិបាកថាណាស់ ខ្ញុំជឿពាក់កណ្តាល ខ្ញុំអត់ជឿពាក់កណ្តាល វាជឿគឺជឿពេញមុខ ហ្អ៎ក!ព្រះពុទ្ធសាសនាដូចថា បើកវ៉ាដ្យូស្តាប់ នៅក្នុងព្រះ

យ៉េស៊ូ ចង់ឆ្កាងចង់អីទៅហើយគេនឹកគុណទៅគឺគេជួយ ហើយខ្ញុំខំជឿយ៉េស៊ូអីដែរគឺធ្លាក់ដើមត្នោត ហើយត្រូវម្ហូតូបុកអីចឹងទៅ តើបានអីទៅជួយ ហ៊្អក! ខ្លះហ្នឹងគ្រាន់តែចូលនឹងគេទៅស្រាប់តែឈឺជិតងាប់ ហើយបានគេជួយ ឯណាបើទៅយកគ្រូមកគគោកគជី ខ្ញុំមិនចង់ជឿទេ! គឺខ្ញុំនិយាយឲ្យចំអញ្ចឹងហ្នង ជឿចំខ្លះទៅគេស្តោះផ្លុំក៏ជាទៅ ខ្លះអា គ្រូមុនស្តោះអត់ជាហើយអាគ្រូគេមកក្រោយស្តោះតែបន្តិចជា ។

ទ្រី: ខ្ញុំមិនសូវដឹងរឿងសាសនាអីដែរណា តែនៅសព្វថ្ងៃបងសឿឯងទៅព្រះពុទ្ធដែរតើ បងសឿដូចជាខ្ញុំដែរតើហ្អី?

សឿ: ខ្ញុំព្រះពុទ្ធហ្នឹងហើយ ។

ទ្រី: ហើយព្រះពុទ្ធហ្នឹង តើនៅត្រង់កន្លែងណាខ្លះដែលប្រដៅមនុស្សឲ្យល្អ?

សឿ: ហ៊្អក! ខ្ញុំអត់ដែលបានស្តាប់គេទេ ខ្ញុំអត់ដែលរាប់រៀបចាំទេ លោកទេសនាមកគឺផ្លូវសុទ្ធតែធម៌តែអារ្យអញ្ចេះ មានហើយ អ្នកឯងគ្រាន់ហើយកុំអាល ហ៊្អែ! មិនដឹងជាអីទេខ្ញុំអត់ចាំទេ រឿងព្រះពុទ្ធសាសនាគឺខ្ញុំអត់ចាំតែហ្នងហើយ ប៉ុនតែថាជឿគឺជឿ ។

រិទ្ធ: ខ្ញុំមើលនៅក្នុងចម្លើយសារភាពហ្នឹងទៅ គឺខ្ញុំឃើញថាអ្នកខ្លះឆ្លើយថាជាសេអ៊ីអា ជាកាសេបេរបស់អាមេរិក របស់ពួក រុស្ស៊ីអីអញ្ចឹងណា ។

សឿ: អ្នកឆ្លើយដែលគេសួរចម្លើយនោះ!

រិទ្ធ: ប៉ា!ៗ ហើយបងសឿឯងយល់ថាបងអ្នកទាំងអស់ហ្នឹង ពិតជាកាសេបេ ជាសេអ៊ីអាមែនហ៊្អែបងសឿ?

សឿ: ទេគឺអត់មានពិត ការដាក់ស្តែងនោះគឺគ្នាឈឺពិតមែនហើយ គ្នាឈឺគឺចាក់គ្នាឡង់ប្រឡាត ឆក់ខ្សែភ្លើងឲ្យគ្នាឆ្លើយពពីស ពពាសតែហ្នងហើយ អត់មានដេការថាគ្នាក្បត់អីគឺអត់ទេ អ្នកនោះគឺគ្នាត្រង់ពិតមែន ប៉ុនតែថាដាក់ខ្សែភ្លើងឆក់គ្នាទៅ គ្នាឆ្លើយទៅជាតែប្តាសថាខ្ញុំជាសេអ៊ីអាមែនពីឆ្នាំ៧០នេះ ឬក៏ជាឆ្នាំ៧២ឬ៧៣អញ្ចឹងទៅ គឺបេះតែឆ្លើយទៅ អាហ្នឹងគឺគ្មានការពិតត្រង់តែថាឃើញគ្នាជាកាសេបេ សេអ៊ីអាអីគឺអត់មានទេ អានេះគឺដោយសារតែឈឺខ្លួនទេ ។

រិទ្ធ: ដល់ពេលដែលគេធ្វើទារុណកម្មឈឺទៅ គឺបេះតែឆ្លើយទៅ?

សឿ: បេះតែឆ្លើយទៅ ។

រិទ្ធ: ចុះបងសឿ បើតាមបងសឿឯងចាំ តើគេមានវិធីអីខ្លះសំរាប់គេធ្វើជាទារុណកម្ម?

សឿៈ អានេះគឺខ្ញុំគ្រាន់តែលឺទេណា មិនបានឃើញជាក់ស្តែងទេ គឺគ្រាន់តែលឺតាមអ្នកដែលធ្វើការជាមួយគ្នាទេណា គ្រាន់តែ គេសួរមកគឺបែកខ្លួន គេឆក់បែកខ្លួនគេវៃបែកខ្លួន ដំបៅអីអញ្ចឹងទៅ ដូចថាគ្នាជាស្រីហើយមិនឆ្លើយអីចឹង គឺដុតគ្នាដំបៅ អីអស់ហើយ ។

រិទ្ធៈ គេយកអីដុតទៅបងសឿ?

សឿៈ ទេ! ខ្ញុំមិនហ៊ានសួរគេទេ គឺគ្រាន់តែគេប្រាប់ប៉ុណ្ណឹង ។

រិទ្ធៈ អញ្ចឹងមានដូចថា យកភ្លើងដុត ឆក់ខ្សែភ្លើង វៃអីហើយក្រៅពីហ្នឹងមានអីទៀតដែលទេបងសឿ?

សឿៈ មានតែជាខ្សែតីអីនោះហើយ ។

រិទ្ធៈ មានដែលយកកាំភ្លើងអីបាញ់ដែលទេ?

សឿៈ ទេ! អត់មានដែលលឺសួរកាំភ្លើងអីទេ បើខ្ញុំនៅដើរនៅខាងក្រៅអត់មានលឺសួរទេ បើលឺសួរគឺអ្នកដែលនៅខាងក្រៅក៏បាញ់ដែរ ពីព្រោះអ្នកដែលនៅការពារនៅខាងក្រៅ ឲ្យស្តាប់លឺនៅខាងក្នុងគឺគេបាញ់ជួយហើយ ប៉ុន្តែអានេះគឺអត់មាន ទេ ។

រិទ្ធៈ អ្នកសួរចម្លើយហ្នឹងប្រុសឬក៏ជាស្រីបងសឿ?

សឿៈ សុទ្ធតែជាប្រុសៗ ។

រិទ្ធៈ អញ្ចឹងអ្នកទោសស្រីៗហ្នឹង ត្រូវអ្នកសួរប្រុសៗហ្នឹងសួរដែរ?

សឿៈ សួរ គេជាអ្នកសួរ គឺអត់មានរឿងថាជាស្រីទេ គឺសុទ្ធតែជាប្រុសៗហើយ ។

រិទ្ធៈ ដូចថាមានស្រីៗអីដែរអញ្ចឹងទៅដើម្បីការពារ

ពីព្រោះនៅសម័យនោះគឺគេគោរពសីលធម៌ណាស់?

សឿៈ ទេ! នៅកន្លែងនោះគឺអត់មានឃើញស្រីៗទេ អ្នកដែលនៅកន្លែងនោះ ហើយខ្ញុំដើរនៅជុំវិញកន្លែងនោះ គឺអត់មានដែលបានឃើញនារីអីមួយទេ គឺគេទៅធ្វើជាពេទ្យអីផ្សេង ដល់ពេលដែលឈឺទៅបានឃើញនៅពេទ្យ គឺអត់មាននារីណា មកឡូកឡំទេ គឺឃើញតែប្រពន្ធកម្មាភិបាល ប្រពន្ធឌុចអីហ្នឹងតែប៉ុណ្ណឹងឯងទៅស៊ីបាយ ក្រៅពីហ្នឹងគឺអត់មានឃើញនារីណាទេ បើទាំងអត់ស្គាល់មុខនារីផងហ្នឹង ។

រិទ្ធៈ ចុះដូចថានារីអីគេសួរចម្លើយរបៀបផ្សេង ហើយនារីអីគេសួររបៀបផ្សេងអី?

សឿៈ អានេះគឺខ្ញុំអត់ដឹងថាគេទៅសួរនៅបន្ទប់ណា ប្រុសណាអីគេទៅសួរគឺខ្ញុំអត់មានដឹងទេ ពីព្រោះខ្ញុំនៅខាងក្រៅគឺខ្ញុំអត់បាន ដឹងទេ ។

រិទ្ធៈ ចុះមានដែលលឺគ្នាអីគេនិយាយដែលទេ?

សឿៈ អត់ដែលទេ ត្រង់ហ្នឹងគឺគេអត់មាននិយាយទេ គឺគេគ្រាន់តែចេញមកបាយណា គេគឺជាអ្នកយាមណា គេគ្រាន់តែថាដុត គ្នាឡើងចុយម៉ាយហើយ សួរអត់ចេញទេ ហើយគឺយើងដឹងតែប៉ុណ្ណឹងទេ ។

រិទ្ធៈ ចុះគេអត់មានថាដុតនៅកន្លែងណាអីទេ?

សឿៈ គេដុតនៅកន្លែងដែលសួរចម្លើយហ្នឹង គ្រាន់តែគ្នាឯងអាពៅអីហ្នឹងគ្នាឯង អាហ្នឹងសុទ្ធតែជាអ្នកត្រង់ហើយណា លាក់ទុកនៅក្នុងខ្លួនគឺមិនឆ្លើយដាក់អ្នកណាទេ ប៉ុនគ្រាន់តែថាដុតដំបៅអស់ហើយ ។

រិទ្ធៈ ដុតឆេះខ្លួនហ្នង?

សឿៈ ដុតឆេះពោះ ឆេះអីអស់ហើយទាល់តែគ្នាឆ្លើយ គឺថាអាត្រូវទៅជាខុសហើយ ហើយដល់ស្អែកឡើងយកគ្នាទៅទៀត យកគ្នាទៅចាក់ថ្នាំហើយយកគ្នាទៅទៀត ។

រិទ្ធៈ អញ្ចឹងពេលដែលដុតគ្នាហើយ យកគ្នាទៅចាក់ថ្នាំ អញ្ចឹងគេមានពេទ្យអីចាក់ថ្នាំឲ្យអ្នកទោសហ្នឹងដែរ?

សឿៈ មានពេទ្យគេនៅក្នុងហ្នង់ទៀតណា ពេទ្យគេអ្នកមើលអ្នកទោសនោះ នៅលាបថ្នាំអីឲ្យចាក់ថ្នាំអីឲ្យអញ្ចឹងទៅ អាហ្នឹងគឺលឺពាក្យគេនៅខាងក្នុងទេណា អាពៅ គេចេញមកគេនិយាយទេណា ខ្សឹបគ្នាស្មោះត្រង់ហើយបានជានៅជាមួយគ្នាបាននោះ កុំអីអត់មាននៅជាមួយគ្នាបានទេ ខ្ញុំលាក់គំនិតលាក់ចិត្ត ហើយវានោះក៏ហ៊ានប្រាប់ គឺវាដឹងចិត្តគ្នាបានហ៊ានប្រាប់គ្នា ដល់តែអញ្ចឹងទៅគឺវាចេះតែប្រាប់ទៅ គឺវាថាមួយបន្ទប់អញយកទៅ៣-៤នាក់ហ្នឹង ស្រេចតែម្នាក់ស្រីនោះគេដុចឆេះ មុខឆេះអីអស់ ពពីពពាលមុខអីអស់ហើយ ។

រិទ្ធៈ ខ្ញុំគេដុតហ្នឹងអី?

សឿៈ វាថាអញអត់ដឹងទេ វាថាអត់ដឹងទេ វាអត់ហ៊ានដែរ អាចំនុចដែលគេដុតគឺវាអត់ឃើញដែរ ពីព្រោះវានៅតែយាមគឺវាអញ្ចឹងទេ គឺគ្រាន់តែប៉ុណ្ណឹងទេ គឺថាពីក្រោមពីលើអីគ្រប់កន្ទុកអីគឺដុតអស់ហើយ តើពីណាមិនឆ្លើយលើសតែពីរដងគឺដុត អាក្នុងកន្ទុកអីអស់ហើយ គឺសើយសំពត់គ្នាដុត គឺថាគ្នាដំបៅអស់មើលនៅក្នុងបន្ទប់ហ្នឹង អាពៅវាជាអ្នកបញ្ចូលទៅក្នុងបន្ទប់ ។

រិទ្ធៈ បងសឿមានដែលលឺថាឌុចហ្នឹងទៅសួរចម្លើយអ្នកហ្នឹងផ្ទាល់ដែលទេ មានដែលលឺពីរឿងហ្នឹងដែលទេ?

សឿៈ ទេ! ខ្ញុំអត់ដែលទេ ការដឹងរឿងគេមេសួរចម្លើយគឺនៅក្នុងហ្នង់ ហើយការសួរចម្លើយក៏នៅក្នុងហ្នង់ដែរ ហើយខ្ញុំវាអត់ហ៊ានចូល ហើយបើរឿងសួរចម្លើយក៏នៅលើឌុចហ្នឹងដែរ នៅក្នុងមន្ទីរ

ហ្នឹងដែរ ប៉ុនតែខ្ញុំអត់ហ៊ានចូល ពីព្រោះការងារ យើងវានៅម្ខាងប៉ែក ដូចដែលខ្ញុំនិយាយពីខាងដើមអញ្ចឹងណា វាប៉ែកៗឲ្យតែហ៊ានចូល គឺគេថាយើងចង់ដឹងគេថាចេះ ដឹងការងារគេអី ហើយបើរឿងថាឌុចអីទៅសួរចម្លើយគឺខ្ញុំអត់មានដឹងទេ?

រិទ្ធៈ បងសឿ តើបងសឿឯងមានដែលឃើញអ្នកទោសក្មេងៗនៅក្នុងគុកទួលស្លែងដែលទេ?

សឿៈ អារឿងអ្នកទោសក្មេងៗគឺខ្ញុំអត់ដែលឃើញទេ មិនដែលឃើញទេ គឺខ្ញុំទើបតែទៅឃើញរូបថតហ្នឹងហើយ ឃើញក្មេងតូចៗនោះ ពីមុនមកគឺខ្ញុំអត់ដែលឃើញទេ គឺឃើញទេមនុស្សធំៗហ្នុង ។

រិទ្ធៈ អញ្ចឹងកាលដែលបងសឿឯងនៅយាមនៅហ្នឹង គឺអត់មានដែលឃើញក្មេងទេ?

សឿៈ កាលដែលខ្ញុំនៅយាមខាងក្រៅហ្នឹង គឺអត់មានដែលឃើញក្មេងទេ អត់មានឃើញដាក់ឡានដាក់អីទេ គឺឃើញតែក្មេងធំៗ ប៉ុនកាលដែលគេឲ្យទៅមើលហ្នឹង ឃើញក្មេងនៅក្នុងរូបថតមានម្តាយអី អាហ្នឹងគឺខ្ញុំវាអត់ដឹងអញ្ចេះ ។

រិទ្ធៈ រូបថតនៅទួលស្លែង?

សឿៈ បាទ! ខ្ញុំវាអត់ឃើញមនុស្សធំមនុស្សតូចអាផេកអាង៉ាកយកមក ដាក់ឡានដាក់អីមកទេ អើបើរូបភាពដែលគេមក ក្រោយនៅពេលដែលខ្ញុំចេញទៅក៏មិនដឹង ពីព្រោះខ្ញុំចេញទៅបានតែមួយឆ្នាំទេនៅក្នុងគុកទួលស្លែង ។

រិទ្ធៈ អញ្ចឹងបងសឿ ឯងចូលក្នុងគុកទួលស្លែងនៅឆ្នាំណាដែរ?

សឿៈ អត់ទេ ខ្ញុំនៅយាមក្នុងគុកទួលស្លែងបានតែមួយឆ្នាំទេ ចេញទៅក្រៅគឺចេញទៅធ្វើស្រែនៅខាងក្រៅនៅពោចិនតុងណោះ នៅកន្លែងពោចិនតុង, អូរបាយក្អមណោះ គេឲ្យដកទៅកន្លែងហ្នឹងវិញ ។

រិទ្ធៈ បងសឿនៅពេលដែលបងសឿឯងចូលទៅគុកទួលស្លែងហ្នឹង ប្រហែលជានៅឆ្នាំណាដែរ?

សឿៈ ៧៦ ខែ២ ។

ទ្រីៈ ដកចេញពីទួលស្លែងទៅ?

សឿៈ អត់ទេ ដកពីនោះមកចូលទួលស្លែង ទល់៧៧ខែ៨ ឆ្នាំ៧៨ខែ៩ គេដកខ្ញុំចេញទៅអូរបាយក្អមទៅធ្វើស្រែនោះ ដល់៧៩ ខែ៧នេះវៀតណាមចូល ។

រិទ្ធៈ អញ្ចឹងបងសឿឯងមានដឹងថាហេតុអីបានជាគេដកបងសឿឯងពីទួលស្លែងហ្នឹងដែលទេ?

សឿៈ អត់ដឹង អត់មានដឹងទេ គេថាឲ្យទៅជួយធ្វើស្រែជួយធ្វើកងចល័តកងអីទៅ គេថាយកកងទ័ពទៅឡូកឡំជួយបំពេញ ភារកិច្ចកសាងអីគេទៅណា ។

រិទ្ធៈ ដល់ពេលដែលទៅពោចិនតុងហ្នឹង តើបងសឿឯងធ្វើអីខ្លះទៅ?

សឿ៖ នៅតែធ្វើស្រែលើកទំនប់ហ្នឹង លើកទំនប់អូរបាយក្អមហ្នឹង ។

រិទ្ធ៖ លើកទំនប់ធ្វើស្រែ ហើយមានធ្វើអីទៀតដែលទេ?

សឿ៖ អត់មានធ្វើអីទៀតទេ ដេកស៊ីហ្នុង គឺមើលម៉ោងស៊ីហ្នុង ។

រិទ្ធ៖ ហើយនៅពោធិ៍ចិនតុងហ្នឹង តើអ្នកណាគេជាអ្នកគ្រប់គ្រង?

សឿ៖ អត់ដឹងទេ ឈ្មោះអីទេគេនៅកងពលជាមួយដែរ គេនៅហ្នុងដែរតែគេជាអនុប្រធាន ប៉ុន្តែខ្ញុំ វាអត់ស្គាល់ ។

រិទ្ធ៖ គេហៅថាតំបន់អី កន្លែងអីដែរកន្លែងហ្នឹង?

សឿ៖ មិនដឹងជានៅតំបន់អីទេ តែខ្ញុំដឹងថានៅកងពលតែមួយ នៅកលពល៧០៣តែមួយអញ្ចឹងហ្នុង ។

រិទ្ធ៖ អរ! អញ្ចឹងកងពល៧០៣?

សឿ៖ បាទ! នៅមួយប៉ែកឡូតែខេត្តភ្នំពេញគឺកងពល៧០៣អញ្ចឹងហ្នុង ។

រិទ្ធ៖ មានដឹងថាមេកងពលហ្នឹងឈ្មោះអីដែរទេបងសឿ?

សឿ៖ ពីមុនតាម៉ុកហ្នឹងហើយ គាត់ជាប្រធានកងពលធំហើយហ្នឹងនោះ តាំងពីស្រុកឃ្លូនមកទល់រត់ទៅ ដល់ប៉ៃលិន, សំឡូតទៅ, ខាងតាំងក្រសាំង, អន្លង់វែងអីហ្នឹង គឺនៅលើគាត់អស់ហើយ គឺគាត់ នៅកាន់កងពល៧០៣ហ្នឹងជាប់ដែរ គាត់ជាប្រធានភូមិភាគ៧០៣ហើយ សាខាអនុកងពល ប្រធានកងពលបញ្ជាររបស់គាត់អីគឺខ្ញុំអត់ដឹងទេណា គឺអត់មានដែលឃើញ ការងាររគាត់ទៅ វៃទៅអីគឺអត់មានដែលឃើញទេ គឺអត់មានឃើញចេញទៅណាអីហ្នឹងគេទេ ។

រិទ្ធ៖ បងសឿនៅពេលដែលបងសឿឯងទៅពោធិ៍ចិនតុងមានដែលឃើញតាម៉ុក ប្រធានកកងពល ៧០៣ អីដែលទេ?

សឿ៖ កាលដែលគាត់នៅពីដើមគឺគាត់អត់កំបុតជើងទេ តែឥឡូវគាត់កំបុត ពីដើមគាត់ស្អាតបោះគាត់ ដែរហ្នឹង ខ្ញុំដើរជាមួយ គាត់ដែរហ្នឹង ។

រិទ្ធ៖ អូរ! បងសឿ ឃើញគាត់ហ្នុង?

សឿ៖ ដែលជិះអាគ្រោះជាមួយគាត់ដែរ ។

រិទ្ធ៖ អូរ! នៅជិតជាមួយគាត់ដែរ?

សឿ៖ អត់ទេ ដូចថានៅពេលបែកអី បែកកង៍ទ័ពចល័តអីគឺទៅជាមួយ ប៉ុន្តែថានៅក្នុងកងពល ជាមួយទេ កងអីខុសគ្នាអញ្ចឹង តែនៅពេលដែលជួបអីជាមួយគាត់គឺស្គាល់គាត់ នៅទៅគាត់ ហៅថាអាអូនហើយគាត់មិនដែលហៅថាមិត្តអីទេ គឺសុទ្ធតែ ជាចៅ ជាកូន បើយើងនៅតូច អញ្ចឹងសុទ្ធតែហៅថាអាអូន ។

រិទ្ធៈ	អញ្ចឹងនៅពេលដែលបងសឿឯងនៅជិះរថក្រោះអីជាមួយគាត់ មានដែលឃើញថាឲ្យយកអ្នកនេះទៅសម្លាប់ យកអ្នក នោះទៅសម្លាប់អី?

សឿៈ	អត់ទេ គឺមានតែបញ្ជារឲ្យទៅវៃយួន បើថាវៃយួនគឺវៃយួនហើយ ។

រិទ្ធៈ	យកកងទ័ពទៅវៃនៅឯណាវិញ?

សឿៈ	ទៅព្រៃនគរ ចេញពីនេះទៅដល់ច្រមុះជ្រូក ទៅដល់ហាណូយដែរណា បានបាក់ពីហ្នឹងមក បានធ្លាក់ទៅបាត់ដំបងចឹង ទៅ មកខាងពាយ័ពអញ្ចឹងទៅ ។

ច្រ៊ីៈ	ចុះបងសឿឯងមានដែលតាម៉ុកចាប់ទៅជាមួយហ្នឹងគេហ្នឹងឯងអីដែលទេ?

សឿៈ	ទៅជាមួយគាត់ដល់ពាយ័ពអញ្ចឹងទៅ ដល់តែខ្ញុំបែកនៅត្រឹមសំឡូតហ្នឹងខ្ញុំរត់មកវិមក ខ្ញុំដកខ្លួនមកអត់បាយ៧យប់៧ថ្ងៃ

ច្រ៊ីៈ	ម៉េចបានដកមកវិញ វៃចេញវៀតណាម?

សឿៈ	បាក់បោះវៀតណាម ។

ច្រ៊ីៈ	ព្រំដែននៅខាងណាដែរបងសឿ?

សឿៈ	ទេ! កាលហ្នឹងមិនដឹងដែរ បើដើរនៅតែក្នុងព្រៃ ។

ច្រ៊ីៈ	តែមានដឹងថានៅក្នុងខេត្តណា?

សឿៈ	ខេត្តបាត់ដំបង តែមិនដឹងជាទៅភូមិណាច្រកឃុំណាគឺខ្ញុំមិនដឹងដែរ បើនៅតែក្នុងព្រៃសុទ្ធតែជាព្រៃភ្នំអីអញ្ចឹង ប៉ុនកាល នឹកឃើញដើរជាមួយគាត់ គឺគាត់ចិត្តល្អណាស់ ។

ច្រ៊ីៈ	តាម៉ុកហ្នឹង?

សឿៈ	ហ្នឹងហើយ បើដល់ពេលបាយគឺឈប់បាយ បើថាងាប់គឺងាប់ទាំងអស់គ្នាកូន មិនថាជាកូនគេកូនអញទេងាប់ៗគឺងាប់ទាំង អស់គ្នាទៅ បើថាយួនបាញ់ងាប់ក៏ងាប់ទៅ ។

ច្រ៊ីៈ	អញ្ចឹងគាត់ចិត្តបានជាមួយកូនចៅ?

សឿៈ	ចិត្តបានណា មិនដែលថាហែ្វងធ្វើកើតទេ បើថាហែ្វងបាញ់មិនកើតបាញ់ហែ្វងចោលឥឡូវអីគឺអត់មានទេ មិនដឹងធ្វើ ម៉េចទេកូនអើយ បើងាប់ក៏ងាប់ទៅបើអាណាចង់ទៅស្គាល់ផ្ទះក៏ទៅៗ អាណាចង់ទៅស្គាល់ភូមិអីក៏ទៅៗ ទៅណាក៏ទៅ គឺគាត់ឲ្យមកអញ្ចឹង បើនៅសល់ប៉ុន្មានគាត់នាំដើរទៅតាមគាត់ក៏ទៅៗ ។

ច្រ៊ីៈ	ពេលដែលគាត់បញ្ជារ នៅពេលដែលថាទៅវៀតណាមនៅខាងណោះខាងណោះអី តើគាត់មានបញ្ជារបន្ថែមអីដែលទេ?

សឿៈ អត់! អត់មានទេ គ្រាន់តែថាជួបវៀតណាមគាត់ថាបើកដូវ បើថាមិនបើកអញ្ចឹងគាត់ថាអាកូនដាក់ទៅ ឆ្ងាយហើយគឺ យើងទំលាយទៅថៃយើង គាត់គ្រាន់តែថាប៉ុណ្ណឹង ។

ទ្រីៈ គាត់មានថាបើជួបវៀតណាមត្រូវតែសម្លាប់ចោល បើជួបស្រីវៀតណាមត្រូវតែរំលោភអីដែលទេ?

សឿៈ អត់ទេ ខ្ញុំនិយាយត្រង់ហើយ គឺគាត់អត់មានថាអញ្ចឹងទេ គាត់កាន់ត្រង់ណាស់អញ្ចឹងបានជាគាត់រស់បោះគាត់នោះ អត់ចេះមានសំដីតូចធំអីទេ បើគាត់សំដីអាក្រក់គឺគាត់ងាប់នៅក្រោមកណ្តាប់ដៃពួកអត់បាយបាត់ហើយ គឺគេបាញ់ចោលបាត់ ប៉ុន្តែគាត់នៅតែសំដីមិនចេះមើលងាយកូនចៅទេ ប៉ុនអារឿងពីមុនមកគឺខ្ញុំអត់មានដឹងទេ ពីព្រោះមនុស្សវាខុសគ្នា អាមកដល់ត្រង់នេះគឺល្អ ហើយទៅត្រង់នោះអាក្រក់ អាហ្នឹងគឺខ្ញុំអត់មានដឹងទេ អាហ្នឹងគឺអញ្ចឹងទៅតែបើខ្ញុំឃើញនៅ មុខគឺខ្ញុំឃើញថាល្អគឺខ្ញុំថាល្អហើយ បើថាអ្នកណាដែលគេថាអាក្រក់គឺដូចជាខ្ញុំនិយាយពីដើមឡើយមកអញ្ចឹង ពីដើមឡើយមកដែលខ្ញុំថាខុចហ្នឹងអាក្រក់ គឺខុចហ្នឹងអាក្រក់ហើយ ជឿខ្ញុំទៅបើខ្ញុំថាល្អគឺល្អហើយ តែនេះគឺខ្ញុំឃើញហ្នឹងមុខខ្ញុំទេណា បើគេក្រៅពីហ្នឹងទៀតគេថាគាត់អាក្រក់ គាត់និយាយមកខ្ញុំល្អ ហើយនិយាយទៅគេនោះអាក្រក់ នោះគឺខ្ញុំអត់មានដឹងទេ ។

ទ្រីៈ ពេលដែលបងសឿឯងមានដែលឃើញទាហានអី ទៅធ្វើបាបប្រជាជនអីស៊ីវិលធម្មតាអីដែលទេកងទ័ពបងសឿឯងអី កូនចៅតាម៉ុកអីហ្នឹង មានដែលឃើញគេសម្លាប់ប្រជាជន ជម្លៀសប្រជាជនអីមានដែលឃើញដែលទេ?

សឿៈ ឆ្នាំប៉ុន្មាន ។

ទ្រីៈ ពេលដែលបញ្ជារឲ្យទៅវៃវៀតណាមអីអញ្ចឹងណា?

សឿៈ អត់មានបញ្ជារឲ្យសម្លាប់អីទេ គឺចិត្តទាំងអស់គ្នាហ្នង ។

ទ្រីៈ តែដូចថាតាម៉ុកគាត់អត់បានបញ្ជារទេ តែកងទ័ពអីគេធ្វើ តើបងសឿឯងមានដែលឃើញទេ?

សឿៈ បាំ! ឲ្យតែគេបាញ់ខ្ញុំ គឺខ្ញុំបាញ់គេវិញហើយ ដួបកាលប៉ុនដូចបងស្រីអីៗហ្នឹងចេញពីរូងមកចាក់ហ្នឹងប្រពុះទង់អីដែលនោះ ចាក់ហ្នឹងប្រពុះទុងដែលនោះណា ទឹងដូចថា ទឹងដូចថាបងឯងឃើញអញ្ចឹងចាក់ទៅ ដួនកាលបាញ់ចោលអញ្ចឹងទៅ ដួនកាលវាបាញ់នារីយើងដែរ ហើយយើងមិនបាញ់នារីវា ។

រិទ្ធៈ តែកាលដែលយើងបាញ់ហ្នឹងគឺវៀតណាមតើ មិនមែនបាញ់ខ្មែរទេ?

សឿៈ បាំទ! បាញ់វៀតណាមទេ ។

រិទ្ធៈ ជួនកាលឃើញអី ចាក់ហ្នឹងប្រពុះទុនអីដែរ?

សឿៈ អាហ្នឹងជួនណាទីនអីដែរ អាហ្នឹងគឺថាគេបាញ់យើង ហើយបាញ់គេវិញដែរ បើថានៅជំនាន់ដែលវៀយួនគឺថាគេក៏សម្លាប់យើង ហើយយើងក៏សម្លាប់គេ ទោះបីកាលហ្នឹងបើទីនសូម្បីតែជាកូនដែលនៅក្នុងអង្រឹងក៏មិនទុកដែរ កូនយួនហ្នឹង ខ្ទមប៉ុនៗហ្នឹង ផ្ទះស្បូវប៉ុនៗហ្នឹង តែវាមិនដឹងជាមូលហេតុអីបានជាយួនវាមកជួយយើងវិញណោះ ហើយខ្ញុំវាបឹក គេតែប៉ុណ្ណឹងទេ ។

រិទ្ធៈ ឆ្ងល់ដែរ ពេលដែលយើងទៅវៃគេអញ្ចឹង ហើយដល់ពេល៧៩ស្រាប់តែមកជួយយើងវិញ?

សឿៈ ឆ្ងល់ដែរ ម៉េចបានជាមកជួយយើងវិញ ស្រេចតែជាននយោបាយអញ្ចឹង អញ្ចឹងបានតែថាពិបាក ។

រិទ្ធៈ ចុះបងសឿឯងម៉េចដែរ មានដឹងគុណវៀតណាមដែលទេ ពេលដែលគេមករំដោះអីអញ្ចឹង?

សឿៈ ខ្ញុំវាអរគុណជាងគេទៅទៀតនោះខ្ញុំ និយាយឲ្យរួមវាអស់ពីជំនាន់យៀកកុងម្ដងហើយ ហើយវៀតណាមគេមកជួយនេះ ជាលើកទីពីរហើយ ។

រិទ្ធៈ បងសឿពេលដែលបងសឿទៅវៃជាមួយហ្នឹងវៀតណាម ដូចដែលបងសឿឯងនិយាយថាពេលខ្លះទីនវៀតណាមហើយ មានបាញ់ចោលអីអញ្ចឹងណា ហ្នឹងបងសឿឯងមានចាំទេថាខេត្តវៀតណាមហ្នឹងនៅត្រង់ណាអីត្រង់ណាដែលទេ?

សឿៈ ខ្ញុំចូលបានត្រឹមតែប្រមុះជ្រូកទេ ។

រិទ្ធៈ ប្រមុះជ្រូកហ្នឹងនៅក្នុងខេត្តណាខ្លះទៅបងសឿ?

សឿៈ នៅក្នុងខេត្តតាយណិញ ។

ថ្មីៈ តាណិយបើទៅពីខាងខ្មែរយើង តើទៅពីខាងណាទៅវិញទៅ?

សឿៈ មិនដឹងពីត្រង់ណាព្រំប្រទល់ខ្មែរទេ បើខ្ញុំមិនដឹងដែរ នៅទាំងយប់ទាំងថ្ងៃនៅតែហ្នឹងដែរ មិនដឹងជាព្រំប្រទល់ខ្មែរយើងអី នៅត្រង់ណាត្រង់ណីអីទេ ប៉ុនកាលដែលទៅគឺទៅតាមផ្លូវអ្នកលឿងហ្នឹង ទៅតាយណិញហ្នឹងទៅ ឡើងទៅព្រៃនគរបន្តិចទៅ បានឈានចូលវៃហាណូយបានតែពាក់កណ្ដាល គឺបានតែបន្តិចទេដែលបាក់មកនោះ អាហ្នឹងគឺរត់មកហើយ ។

រិទ្ធៈ ពេលដែលឃើញវៀតណាមហើយបាញ់សម្លាប់ចោលអីអញ្ចឹងណា តើបងសឿឯងមានដែលឃើញពួកកូនទាហានអស់ ហ្នឹងរំលោភស្រីៗវៀតណាមអស់ហ្នឹងទេ?

សឿៈ ទេ! បើនៅពេលយប់អីខ្ញុំមិនដឹងដែរ អារឿងអស់ហ្នឹងគឺខ្ញុំមិនដឹងដែរ អារឿងរំលោភ រឿងអីគឺខ្ញុំអត់ដឹងដែរ អារឿងកូនទាហានអស់ហ្នឹងខ្ញុំថាអត់ហ៊ានទេ រាក់ទាកដែរហ្នឹង គ្រាន់តែឃើញ

សម្លាប់អស់មួយផ្ទះអីហើយនៅសល់មួយពីរអីគឺគេដក ចោលអស់ហើយ អើខ្ទមតូចៗនោះណា ។

រិទ្ធៈ ខ្ទមមួយនៅប៉ុន្មានអ្នកដែរ?

សឿៈ មួយគ្រួសារៗ ។

រិទ្ធៈ មួយគ្រួសារៗហ្នឹងប៉ុន្មាននាក់?

សឿៈ ដូចថាយើងទៅដល់ខ្សែក្រវ៉ាត់ទីក្រុងតាយណិញអញ្ចឹងទៅ មានកងស្វាយយ័តគេអីនៅយាមអញ្ចឹង ដូចថានៅតាមផ្ទះអី មានកាំភ្លើងមួយដើមអញ្ចឹងទៅ ហើយចូលទៅគឺវៃតាមអាខ្ទមហ្នឹងរួចបានចូលទៅក្នុង ។

រិទ្ធៈ វៃកាលហ្នឹងបានចូលទៅជ្រៅដែលទេ កាលដែលវៃហ្នឹង?

សឿៈ វៃកាលហ្នឹងចូលដល់ហ្នឹងទៅណា បើថាចូលដល់គឺដល់បើថាចូលមិនដល់គឺរត់មកណា អាហ្នឹងគឺវាតាមលទ្ធភាពវៃដែរ ។

រិទ្ធៈ អញ្ចឹងវៃច្រើនដងហ៊្អែបងសឿ?

សឿៈ អើ! ខ្ញុំឈ្លាមដែរហ្នឹងណា ។

រិទ្ធៈ កាលដែលវៃហ្នឹងចុង៧៨ដែរហ្នឹង?

សឿៈ ខ្ញុំទៅពីនេះទៅចូលជិតដល់៧៨ហើយ តែពេលដែលខ្ញុំចេញពីនេះទៅនៅ៧៦ មើលខ្ញុំចេញទៅ៧ មករា ពេលដែលគេរំ ដោះភ្នំពេញបានហ្នឹង គឺខ្ញុំចេញទៅហើយ ។

រិទ្ធៈ ទៅ៧៥ឬក៏៧៩?

សឿៈ ទៅ៧៥ ។

រិទ្ធៈ អរ! ទៅ៧៥ ១៧មេសាហ្នឹង?

សឿៈ ហ្នឹងហើយ កាលដែលរំដោះភ្នំពេញរួចអស់នោះ គឺគេបញ្ជូនឲ្យទៅការពារនៅព្រំប្រទល់ហ្នឹងហ្មងហើយ ។

ថ្វីៈ ហើយប៉ុន្មានទៅបានចូលទួលស្លែងវិញ?

សឿៈ ដកមកហ្នឹង គេដកមក៧៦ខែ...ដូចដែលខ្ញុំនិយាយមិញភ្លេចបាត់ទៅទៀតហើយ កាលដែលវាឲ្យមកហ្នឹងវាឲ្យរៀននៅ ហ្នឹងព្រែកហូររួចសិន រៀនបានបីថ្ងៃ........កន្លះ ហើយពេលដែលវាបញ្ជូនមកហ្នឹងគឺវាអត់ឲ្យយើងស្គាល់ទេ គឺវាបញ្ជូន យើងមកនៅម៉ោងប្រហែលជា៥ល្ងាចគឺវាបញ្ជូនឡានទៅហើយ ។

វីណាៈ ចុះនៅពេលវៃអីអញ្ចឹង គេមានដែលចាប់ក្មេងៗទៅសម្លាប់ដែរអត់?

សឿៈ យួន! ។

វីណាៈ ចាស៎! ។

សឿៈ អត់មានចាប់ទេ បោះចោលចាក់ច្រពុះទុនបាញ់ចោលនៅហ្នឹងហើយ អត់មានចាប់យកទៅចិញ្ចឹមអីនៅឯណាទេ ។

វីណាៈ អញ្ចឹងឃើញភ្លាមសម្លាប់ភ្លាម?

សឿៈ គ្រាន់តែម្តាយឪពុកវាបាញ់យើងអញ្ចឹង យើងបាញ់ឪពុកម្តាយវាងាប់ចោល ហើយបាញ់ចោលទាំងអស់បណ្តោយទៅ

វីណាៈ ឲ្យតែក្មេងៗក៏ដោយ?

សឿៈ ចុះយើងមិនដឹងជាធ្វើម៉េច ហើយអាណាយកទៅចិញ្ចឹមបើឪពុកម្តាយវាងាប់អស់ហើយ មានតែបាញ់ចោលបណ្តោយ

វីណាៈ ពូឃើញផ្ទាល់ភ្នែកហ្នឹង?

សឿៈ បា៎! បេយួនគឺខ្ញុំឃើញផ្ទាល់ភ្នែកហ្នឹង ប៉ុនគ្រាន់តែថានៅវៃនៅនោះទេ បើថាវៃនៅនេះគឺខ្ញុំអត់មានដឹងទេ នៅតាមនេះ គឺខ្ញុំអត់ដែលបានប្រទះទេ ប្រហើយ.....ទៅ ។

វីណាៈ ហើយចុះកាលហ្នឹងអ្នកណាគេជាអ្នកសម្លាប់?

សឿៈ អើគេនៅហ្នឹងគ្រាប់កាំភ្លើងប្រវេកប្រវ៉ាក់ទៅហើយ ។

រិទ្ធៈ ទ័ពតាម៉ុកដែលបញ្ជូនទៅហ្នឹង?

សឿៈ ហ្នឹងហើយ មិនថាអ្នកនេះធំ អ្នកនេះតូចទេ ចុះបើគេបាញ់យើងគឺយើងមិនបាញ់គេ អ្នកឯងបានក៏ខ្ញុំបាន ។

រិទ្ធៈ តែអ្នកទាំងអស់ហ្នឹងជាប្រជាជនធម្មតាតើ គេមានកាំភ្លើងពីណាមក?

សឿៈ មានកាំភ្លើង ។

រិទ្ធៈ គេមានដែរ?

សឿៈ ហ៊ឺ! កាំភ្លើងមានគ្រប់ផ្ទះ វេវីដេ ហៃបអឹម ។

រិទ្ធៈ តែអ្នកទាំងអស់ហ្នឹងជាទាហានវៀតណាមទេបងសឿ?

សឿៈ ជាទាហាន តែគេហៅថាជាកងស្វាយត្រានគេ ដូចថាការពារទីក្រុងតាយណិញអញ្ចឹង គេដាក់ក្រវ៉ាត់ឲ្យនៅការពារនៅ ខាងក្រៅអញ្ចឹង នៅតាមផ្លូវក្រៅអញ្ចឹងណា ដូចថាភ្នំពេញអញ្ចឹងគេដាក់ទាហានឲ្យនៅការពារនៅខត្តុងអញ្ចឹង នៅតាមផ្លូវក្រៅៗការពារទីក្រុងអញ្ចឹងណា ហើយយើងវៃអាក្រៅហ្នឹងណា ។

វីណាៈ កាលហ្នឹងនៅឆ្នាំណាដែរ?

សឿៈ កាលហ្នឹងឆ្នាំ៧៦ តែវៃកាលហ្នឹងវៃខ្សោយដែរមិនទាន់ខ្លាំងទេ។

រិទ្ធៈ វៃបានប៉ុន្មានគីឡូម៉ែត្រពីព្រំដែនដែរបងសឿ?

សឿៈ វៃបានឆ្ងាយដែរ ប្រហែលពីនេះទៅសាលាដែរ បានទៅដល់ទីក្រុងហើយពួកខ្មែរក្រហ៊ាត់វា នៅត្រឹមនេះទៅ នៅត្រឹម សាលាលេខប្រាំយើងហ្នឹង។

រិទ្ធៈ អញ្ចឹងបានឆ្ងាយដែរ?

សឿៈ ឆ្ងាយ ទៅកាលហ្នឹងឆ្ងាយណាស់ ទៅដល់ទីក្រុងហាន់ណូយពីខ្មែរក្រហ៊ាត់គាយណិញទៅ។

រិទ្ធៈ បងសឿ តើបងសឿឯងហ៊ានសន្និត់ទេ ថាពួកកូនទាហានដែលសម្លាប់អីអស់ហ្នឹង រ តើជាពួកស៊ីវិលឬក៏ជាទាហាន?

សឿៈ ជាទាហាន។

រិទ្ធៈ ជាទាហានហ្នង?

សឿៈ សុទ្ធតែជាទាហានទេ បើប្រជាជនធម្មតាអីគឺអត់មានប៉ះទេ ប្រជាជនគឺនៅតែគេនៅចិញ្ចឹងទាអីធម្មតា។

រិទ្ធៈ យើងអត់មានធ្វើបាបទេ?

សឿៈ ប៉ា! វាអត់បាញ់យើង ហើយយើងក៏អត់បាញ់វាដែរ ហើយវាបាញ់តែពីលើផ្ទះមកដែរ បានជាយើងបាញ់នោះ។

វីណាៈ ច្រើនដែលទេពូកាលហ្នឹង?

សឿៈ ទេ! ខ្ញុំកាលហ្នឹងគ្រប់កន្លែងដែលកាលហ្នឹង ដូចថាមួយមុខសញ្ញាដែលខ្ញុំវៃអញ្ចឹង ដូចថាប៉ះផ្ទះបីគឺទាំងបីអញ្ចឹងទៅ បើអា នោះគេពីរតាមពីរអញ្ចឹងទៅ សម្លាប់ដុតផ្ទះអញ្ចឹងទៅ កាលណាវារត់រួចទៅក្នុងអត់ដេញវាទៅ បើអាណារត់មិនរួច...។

រិទ្ធៈ ប៉ុនភាគច្រើនបើហ៊ានតែបាញ់យើងហើយ គឺមួយផ្ទះហ្នឹងគឺទាំងអស់ហ្នង?

សឿៈ បើវាអត់រត់គឺទាំងអស់ហ្នឹងហើយ បើថាវារត់រួចរត់ទៅ រត់ទៅក្នុងវិញគឺរួចហើយ យើងអត់មានដេញ ទៅទៀត ទេ ពីព្រោះយើងខ្លាចដែរ។

វីណាៈ មួយគ្រួសារមានក្មេងគ្រប់គ្រួសារដែលទេពូ?

សឿៈ អត់ទេ ខ្លះទើបតែហ្នឹងការហើយប្ដីធ្វើជាទាហានអីអញ្ចឹងទៅ ហើយខ្លះអីមាននៅជាមួយឪពុកម្ដាយតូចៗអីអញ្ចឹងទៅ ណា។

វីណាៈ គិតទៅភាគច្រើនឬក៏ជាភាគតិចក្មេងដែលនៅតាមគ្រួសារ?

សឿៈ ដូចខ្ញុំមានកូនខ្ញុំអញ្ចឹងទៅ ហើយខ្ញុំធ្វើជាហានហើយនៅជាមួយកូនខ្ញុំអញ្ចឹងទៅ ដល់តែពេលណាដែលផ្ទះណាគេទើបតែ មានប្ដីប្រពន្ធ ហើយគេមានកាំភ្លើងឲ្យទៅ ហើយពាក់អាវឲ្យអញ្ចឹងទៅ ជួនណាទៅវាគិរិះរបស់វាគឺវារត់អញ្ចឹងទៅ វារត់ចូលទៅក្នុងបាត់អញ្ចឹងទៅ គឺវារួចខ្លួនវាទៅគឺវាអញ្ចឹងទេ ។

រិទ្ធៈ ចុះនៅពេលដែលយើងវៃវៀតណាមអញ្ចឹង តើវៀតណាមគេមានវៃមកវិញដែលទេបងសឿ?

សឿៈ មាន គ្នាយើងស្លាប់អស់ច្រើនដែរណា ។

រិទ្ធៈ កាលពេលដែលគេដេញហ្នឹង តើបងសឿឯងអីរត់មកដល់ត្រឹមណាដែរ?

សឿៈ រត់មកដល់ត្រឹមខ្មែរគ្រៀមយើងវិញទៅណា មកនៅជាប់ហ្នឹងគាយណិញវិញហ្នឹងហើយ ។

រិទ្ធៈ ចុះវៀតណាមគេមានដេញប្រហួសមកទៀតដែលទេ?

សឿៈ អត់ហ៊ានទេ គឺវានៅទប់នៅហ្នឹងហើយ ពីព្រោះមកដល់ខ្មែរគ្រៀមយើងហើយ ។

រិទ្ធៈ ចុះកងទ័ពវៀតណាអស់ហ្នឹង មានសម្លាប់ប្រជាជនខ្មែរដូចកាលដែលយើងសម្លាប់ប្រជាជនវាដែលទេ?

សឿៈ ទេ! អានេះគឺខ្ញុំថាអត់មានឃើញទេ តែបើថាវាចាប់បានគឺវាសម្លាប់ដែរណា ដូចទ័ពនារីខ្មែរយើងពេលដែលវាចាប់បាន ហើយព័ទ្ធជាប់ គឺវាចាប់យកទៅបាញ់ចោលអញ្ចឹងដែរទៅណា គឺវាមានបាញ់ចោលដូចតែគ្នាហ្នឹង ។

វីណាៈ ចុះមានដែលចាប់យកមកធ្វើជាឈ្លើយសឹកអីដែលទេ?

សឿៈ ចាប់ខ្មែរយើងហ្នឹង ។

វីណាៈ អត់ទេ! ដូចថាពូប្រយុទ្ធបាញ់គ្នាជាមួយពួកវៀតណាមអីអញ្ចឹង ហើយចាប់ពួកវៀតណាមយកទៅធ្វើជាឈ្លើយអី ដែលទេ?

សឿៈ មានចាប់ណា បានជាមាននៅក្នុងគុកទួលស្លែង អញ្ចឹងបានតែថាមានយួនចូលមកមួកគោបអីគឺចាប់ពីហ្នង់មកណា ។

វីណាៈ ចាប់ពីពេលហ្នង់មក?

សឿៈ ហ្នឹងហើយ ចាប់នៅពេលដែលយើងពទ្ធ័ជាប់នោះណា ។

ទ្រីៈ ហើយចុះពូមានបានឃើញផ្ទាល់ដែលទេ ពេលដែលគេចាប់មកអញ្ចឹង?

សឿៈ ខ្ញុំអត់មានបានឃើញផ្ទាល់ទេ គ្រាប់តែខ្ញុំលឺគេនិយាយ ពេលដែលគេពទ្ធ័គឺខ្ញុំគេដកយកមកអីហ្នឹងហើយ ពេលដែលគេ ចាប់បានយួនធ្វើជាឈ្លើយសឹកហ្នឹង គឺគេយកមកដាក់នៅទួលស្លែងហ្នឹងដែលខ្ញុំនិយាយហ្នឹង បើនិយាយទៅវានាំពិបាក និយាយទៅវានាំតែវែង បើនិយាយពីឈ្លើយ

សឹកហ្នឹងគឺនៅឆ្នាំ៧៧-៧៨ គឺគេបង្ខំចាប់អាឈ្លើយសឹកយួនហ្នឹងមក ហើយ គឺនៅកំពុងពេញ វ៉ៃ៧៨ហ្នឹងហើយ ខ្មែរក៏ប្រឹងសម្លាប់ខ្មែរ ហើយយួនក៏ប្រឹងសម្លាប់យួនដែរ គឺគេបោសសំអាតហើយ ។

រិទ្ធៈ ហើយកាលដែលបងសឿងនៅកងពល៧០៣ទៅវ៉ៃយួនហ្នឹង តើបងសឿងមានឋានៈជាអីដែរពេលដែលទៅបោស សំអាតយួនទៅវ៉ៃយួននោះ?

សឿៈ ខ្ញុំជាកូនទាហាន គឺតូចតែមួយទេហើយគេហៅថាជាយុទ្ធជន តែមិនដឹងជាយុទ្ធជនអីទេ ។

រិទ្ធៈ ប៉ុននៅក្នុងកងពល៧០៣?

សឿៈ បាទ! ហើយជាយុទ្ធជនហ្នឹងគឺនៅតូចជាងកូនខ្ញុំអានេះទៀត អាយុ១២ខ្ញុំទៅ ................ ។

វីណាៈ ចុះនៅក្នុងភូមិហ្នឹងមានគេចូលទៅធ្វើអញ្ចឹងច្រើនដែលទេពូ?

សឿៈ នេះទៅជាមួយខ្ញុំនេះគឺមានអានេះស្និទមួយ អានេះទៅមុនទេ ... អរ! គេទៅក្រោយទេ ខ្ញុំទៅមុនគេបន្តួសហើយ ទៅជាមួយឈ្មោះសៀកនេះ ហើយដល់តែសៀកនេះទៅជាមួយនៅក្នុងកងពល៧០៣ដែរ តែវានៅខាង៩០២វាទៅឈរ ជើងនៅខាងឡាវណោះ ទៅនៅព្រំប្រទល់ខាងឡាវណោះ ។

រិទ្ធៈ សៀកហ្នឹងទៅខាងកងពល៩០២?

សឿៈ បាទ! ទៅទប់នៅខាងឡាវណោះ ដែងគេជារដ្ឋករ ប៉ុនដែងចេញពីនេះទៅគឺនៅជាមួយហ្នឹងខ្ញុំរហូត បានតែខ្ញុំថា ហើយវាអត់ស្លាប់តែពីរអ្នកហ្នឹងទៀតណា ក្រៅពីហ្នឹងស្លាប់ជិតអស់ ។

រិទ្ធៈ ឥឡូវខ្ញុំត្រឡប់មករឿងនេះនេះវិញ គឺតាម៉ុកនេះវិញ ដែលបងសឿងថាគត់ជាមនុស្សល្អអីអញ្ចឹងណា ហើយដល់ ពេលដែលមានតុលាការកើតឡើងនេះ តើបងសឿងយល់ថាម៉េចដែរ តើបងសឿងចង់ឲ្យគេកាត់ទោសគាត់ដែលទេ

ពីព្រោះបងសឿងថាគាត់ចិត្តល្អជាមួយកូនចៅអីអញ្ចឹង?

សឿៈ ទេ! ខ្ញុំបើថាតាមច្បាប់ បើច្បាប់ឯកភាពអ្នកដែលធ្វើសាក្សីរបស់គាត់ បើថាឲ្យកាត់ទាំងអស់គ្នាអាហ្នឹងគឺខ្ញុំឯកភាព បើគេកាត់តែខ្ញុំ ហើយទាំងអស់គ្នាគេថាមិនបាច់កាត់ទាំងអស់គ្នាទេ ក៏ខ្ញុំឯកភាពតាមគេដែរ ។

រិទ្ធៈ អត់ទេគឺខ្ញុំចង់ដឹងពីបងសឿង?

សឿៈ ខ្ញុំសុខចិត្ត បើថាកាត់គឺឲ្យកាត់តែទាំងអស់តែហ្នឹងទៅ ដូចដែលខ្ញុំនិយាយពីដើម បើថាកាត់គឺកាត់ឲ្យជាប់តែទាំងអស់តែ ហ្នឹងទៅអ្នកធំៗហ្នឹង អាហ្នឹងគឺខ្ញុំឯកភាពកាត់តែហ្នឹង ជាសាក្សីកាត់ទាំងអស់តែហ្នឹង បើថាកាត់តែគាត់គឺកុំកាត់គាត់គឺខ្ញុំ អត់មានឯកភាពទេ ។

*រិទ្ធៈ អញ្ចឹងបើថាកាត់តែគាត់គឺអត់ឯកភាពទេ?*

*សឿៈ ខ្ញុំអត់ឯកភាពទេ ។*

*រិទ្ធៈ បើកាត់តែឯងគឺអត់សុខចិត្តទេ បើថាកាត់ទាំងអស់គឺឲ្យកាត់ចុះ?*

*សឿៈ បា៎! កាត់ចុះ ខ្ញុំជាសាក្សីហើយ ។*

*រិទ្ធៈ កាត់ទាំងអស់ហ្នឹង តើគាត់ម៉េចដែរ?*

*សឿៈ កាត់អ្នកធំៗហ្នឹង សេនៗអីហ្នង់ ដែលជាមេឲ្យគាត់មកហ្នឹង បន្ទាប់មកកាត់ទាំងអស់តែហ្នុងទៅ គឺមានតែប៉ុណ្ណឹង ។*

**ចប់**